**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/១/០៧-០៩-២០០៩-អវតក/កសចស(អបជ ៥០)
**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ
**ថ្ងៃដាក់** : ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jul-2018, 15:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ:**
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:** សាធារណៈ:/Public
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

# ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ក្នុងសំណុំរឿង០០៤/១**

**សហមេធាវី អ៊ឹម ចែម:**
ប៊ិត ស៊ាងលឹម
Wayne JORDASH

## ការឆ្លើយតប

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម[1] (ចម្លើយតប) ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញា[2]("បណ្តឹងឧទ្ធរណ៍") ប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ)របស់សហចៅក្រមស៊ើបអង្កេត ("សចស")[3]។

២. ដូចបានពន្យល់ខាងក្រោម ចម្លើយតបលើកយកតែការអះអាងផ្នែកអង្គហេតុដែលមិនត្រឹមត្រូវ និងគោលការណ៍ច្បាប់ដែលខុស។ ចម្លើយតបរបស់ អ៊ឹម ចែម មិនបានលើកពីអំណះអំណាងដែលបដិសេធកំហុសឆ្គងផ្នែកច្បាប់ អង្គហេតុ និងបញ្ហាចម្រុះទាំងច្បាប់និងអង្គហេតុ ដូចបានលើកនៅក្នុងបណ្តឹងឧទ្ធរណ៍។ កំហុសទាំងនេះអាចដោះស្រាយបានតែតាមរយៈការបញ្ជូនសេចក្តីសម្រេចស្តីពីយុត្តាធិការបុគ្គលទៅ សចស ដើម្បីពិចារណាឡើងវិញ ឬ តាមរយៈអង្គបុរេជំនុំជម្រះខ្លួនឯងក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចស្តីពីយុត្តាធិការបុគ្គល។

## I. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាបានពឹងផ្អែកលើបទដ្ឋានដែលត្រឹមត្រូវនៃការត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍

៣. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា បានកំណត់អត្តសញ្ញាណកំហុសឆ្គងផ្នែកច្បាប់ អង្គហេតុ និងកំហុសឆ្គងចម្រុះនៃច្បាប់ និងអង្គហេតុមួយចំនួន នៅក្នុងដីកាដំណោះស្រាយ(សំអាងហេតុ)។ ចម្លើយតបរបស់ អ៊ឹម ចែម ទាមទារថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា គឺខ្វះលក្ខណៈគ្រប់គ្រាន់នៅក្នុងនោះ ធ្វើឱ្យវា "បរាជ័យនៅក្នុងការតវ៉ាទៅលើបទដ្ឋានត្រួតពិនិត្យដែលត្រឹមត្រូវ"[4] ដែលអនុវត្តបានចំពោះសេចក្តីសម្រេចឆន្ទានុសិទ្ធិ។

៤. អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសាលដីកាបណ្តឹងសាទុក្ខនៃសំណុំរឿង០០១ បានសម្រេចថា ការកំណត់ថាតើបុគ្គលម្នាក់គឺជា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិតេយ្យឬអត់ គឺជាសេចក្តីសម្រេចឆន្ទានុសិទ្ធិមួយដែល

---

1 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ), ២២ កញ្ញា ២០១៧ ("ចម្លើយតបរបស់ អ៊ឹម ចែម")។

2 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ), ៩ សីហា ២០១៧ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា")។

3 **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), ១០ កក្កដា ២០១៧ ("ដីកាដំណោះស្រាយ(សំអាងហេតុ)")។

4 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨។

ភាគច្រើនសម្រាប់សេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា និង សចស[5]។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាមិនបានស្នើឲ្យអង្គបុរេជំនុំជម្រះ យកសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាស្តីពីថាតើ អ៊ឹម ចែម ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ទៅជំនួសសេចក្តីសម្រេចរបស់ សចស ទេ។ ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាផ្តោតទាំងស្រុងទៅលើកំហុសឆ្គងដែល សចស បានធ្វើការបកស្រាយច្បាប់និងអង្គហេតុនានា- ជាកំហុសឆ្គងដែលបន្ទាប់មក សចស បានប្រើប្រាស់ក្នុងការអនុវត្តសេចក្តីសម្រេចរបស់ខ្លួនចំពោះ អ៊ឹម ចែម ថាតើគាត់ជា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែរឬអត់។ ខណៈដែលអង្គជំនុំជម្រះពិនិត្យបណ្តឹងឧទ្ធរណ៍ គួរផ្តល់ឲ្យចៅក្រមតុលាការជាន់ទាបនូវសេរីភាពក្នុងការប្រើសេចក្តីសម្រេចផ្ទាល់ខ្លួន នៅក្នុងសេចក្តីសម្រេចឆន្ទានុសិទ្ធិក៏ដោយ តែសេចក្តីសម្រេចឆន្ទានុសិទ្ធិមួយដែលបានពឹងផ្អែកលើការបកស្រាយខុសចំពោះច្បាប់ ឬដែលធ្វើមិនដឹងមិនឮចំពោះអង្គហេតុដែលពាក់ព័ន្ធ មិនអាចទទួលបានសិទ្ធិនេះឡើយ។

*(i) អ៊ឹម ចែម បកស្រាយខុសចំពោះបទដ្ឋាននៃការត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចឆន្ទានុសិទ្ធិ*

៥. អង្គបុរេជំនុំជម្រះបានកំណត់ជាបីផ្អែកតាំងពីមុន នៅក្រោមសេចក្តីសម្រេចឆន្ទានុសិទ្ធិដែលអាចប្តឹងឧទ្ធរណ៍បាន: (i) ផ្អែកលើកំហុសឆ្គងផ្នែកច្បាប់; (ii) ផ្អែកលើកំហុសឆ្គងផ្នែកអង្គហេតុ និង (iii) ប្រសិនបើមានការរំលោភឆន្ទានុសិទ្ធិ[6]។ ប៉ុន្តែ អ៊ឹម ចែម ណែនាំនូវលក្ខខណ្ឌតម្រូវពីរយ៉ាងទាំងមានកំហុសសម្រាប់ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចឆន្ទានុសិទ្ធិ។ អ៊ឹម ចែម ទាមទារទាំងមិនត្រឹមត្រូវថាគេត្រូវតែមានភ័ស្តុតាងបញ្ជាក់ពីកំហុសផ្នែកច្បាប់ ឬ អង្គហេតុនោះ *ហើយជាការបន្ថែម* កំហុសផ្នែកច្បាប់ ឬអង្គហេតុនោះ បានបង្កឲ្យមានការរំលោភឆន្ទានុសិទ្ធិ[7]។

---

[5] សំណុំរឿង០០១-**F28** សាលដីកាសម្រេចលើបណ្តឹងសារទុក្ខក្នុងសំណុំរឿង០០១, ៣ កុម្ភៈ ២០១២, កថាខណ្ឌ ៧៩។

[6] សំណុំរឿង០០២-**A371/2/12** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសុំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ១១ មិថុនា ២០១០, កថាខណ្ឌ ២២។

[7] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៧។

៦. ចំណុចនេះ គឺជាការអានដោយយល់ច្រឡំយ៉ាងច្បាស់ក្រឡែតចំពោះច្បាប់ជាធរមានដែល អ៊ឹម ចែម លើកយោង[8] និងរកមិនឃើញការគាំទ្រនៅក្នុងយុត្តិសាស្ត្រ។ គេគ្មានលក្ខខណ្ឌតម្រូវដែលថា កំហុសឆ្គងផ្នែកច្បាប់ ឬអង្គហេតុ នៅពេលត្រូវបានកំណត់ហើយនោះ ត្រូវតែ"មានតម្លៃស្មើនឹងការរំលោភឆន្ទានុសិទ្ធិ" ក្នុងពេលដំណាលគ្នា ដើម្បីអាចពិនិត្យបាននោះឡើយ[9]។ អ៊ឹម ចែម កំពុងតែធ្វើការអះអាងយ៉ាងមានប្រសិទ្ធភាពថា ចៅក្រមមានឆន្ទានុសិទ្ធិធ្វើឱ្យច្បាប់ និងអង្គហេតុទៅជាខុស។ បន្ទាប់ពីមានតក្កវិជ្ជារបស់ អ៊ឹម ចែម មក គេគ្មានបញ្ហាអ្វីទាំងអស់ ទោះបីជាមូលដ្ឋានច្បាប់សម្រាប់សេចក្តីសម្រេចមួយមិនត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏ភាគីគ្មានលទ្ធភាពប្តឹងឧទ្ធរណ៍ ឬអង្គបុរេជំនុំជម្រះអាចពិនិត្យបានដែរ ឱ្យតែវាបានបង្ហាញផងដែរថា សេចក្តីសម្រេចនោះគឺជាការរំលោភឆន្ទានុសិទ្ធិ។ ប្រសិនបើសេចក្តីសម្រេចឆន្ទានុសិទ្ធិ បានធ្វើការសន្មតតាមការបកស្រាយខុសនៃច្បាប់ ឬរបកគំហើញផ្នែកអង្គហេតុដែលមានកំហុសទាំងស្រុង នោះគេគ្មានមធ្យោបាយអ្វីសម្រាប់ឱ្យអង្គជំនុំជម្រះដែលមានតួនាទីពិនិត្យបណ្តឹងឧទ្ធរណ៍បានដឹងអំពីកំហុសឆ្គង ដែលបានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសេចក្តីសម្រេចនោះទេ ហើយវាក៏នឹងតម្រូវអង្គជំនុំជម្រះពិនិត្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការស្មានពិតប្រាកដមួយ ដើម្បីទាយអំពីរបៀបដែលត្រូវអនុវត្តសេចក្តីសម្រេចឆន្ទានុសិទ្ធិដែលបានធ្វើឱ្យប៉ះពាល់ដោយកំហុសឆ្គងនោះ។ អ៊ឹម ចែម ពឹងផ្អែកលើបទដ្ឋានពិនិត្យបណ្តឹងឧទ្ធរណ៍បែបកែឆ្នៃ និងមិនត្រឹមត្រូវនេះនៅពាសពេញចម្លើយតបទាំងមូល[10]។

### *(ii) អ៊ឹម ចែម បង្ហាញចរិកលក្ខណៈខុសចំពោះវិសាលភាពនៃសិទ្ធិអំណាចត្រួតពិនិត្យរបស់អង្គបុរេជំនុំជម្រះ*

៧. ផ្ទុយនឹងការអះអាងរបស់ អ៊ឹម ចែម[11] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាបានបង្ហាញអំពីផលប៉ះពាល់ និងអនុភាពនៃកំហុសឆ្គងនិមួយៗដែលបានចោទប្រកាន់ - មានដូចជាដើម្បីបន្ទាបការវាយតម្លៃរបស់ សចស អំពីយុត្តាធិការបុគ្គល[12]។ ដូចសហព្រះរាជអាជ្ញាបានតវ៉ា គឺថាកំហុសផ្នែកច្បាប់ អង្គហេតុ និងកំហុសឆ្គងចម្រុះនៃច្បាប់និងអង្គហេតុ ដូចបានរៀបរាប់យ៉ាងលម្អិតនៅក្នុង

---

[8] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ១៣, ១៤។

[9] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៩។

[10] *សូមមើល* ជាឧទាហរណ៍ **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣, ៧, ៩, ១៥, ៤១, ៤៥, ៤៦, ៥១, ៥៥, ៦១, ៧២, ៧៣, ៧៦, ៨៥, ៨៧, ៩០, ៩៣, ៩៦, ៩៩, ១០២, ២០៤, ១០៥, ១២៥។

[11] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ១៥។

[12] **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា។

បណ្តឹងឧទ្ធរណ៍ ចាំបាច់ត្រូវតែមានការវាយតម្លៃជាថ្មីលើយុត្តាធិការបុគ្គល ដោយផ្អែកលើច្បាប់ និង អង្គហេតុដែលត្រឹមត្រូវ[13]។

៨. គោលជំហររបស់ អ៊ឹម ចែម គឺមិនគោរពចំពោះយុត្តិសាស្ត្រពាក់ព័ន្ធរបស់ អ.វ.ត.ក ឡើយ។ ទីមួយ អង្គបុរេជំនុំជម្រះអាចដឹកនាំការត្រួតពិនិត្យដូច្នេះបានដោយខ្លួនឯង។ អង្គបុរេជំនុំជម្រះបាន កត់សំគាល់ថា វិធាន៧៩(១) នៃវិធានផ្ទៃក្នុង[14]៖

> ស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះ ស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំជម្រះ៖ "អង្គជំនុំ ជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើប អង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។ នៅក្នុងសន្ទានុក្រមនៃវិធានផ្ទៃក្នុង ពាក្យថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" សំដៅលើ "ដីកាដំណោះស្រាយដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេត ឬ តាមសាលដីការបស់អង្គបុរេជំនុំជម្រះ បញ្ជូនជនត្រូវចោទទៅ ជំនុំជម្រះ"[15]។

៩. អង្គបុរេជំនុំជម្រះបានបង្ហាញគោលជំហររបស់ខ្លួននៅ អ.វ.ត.ក ស្មើនឹងតួនាទីរបស់សភាស៊ើបសួរ កម្ពុជា និងថាស្របតាមមាត្រា២៧៧ និង ២៨១(៣) នៃក្រមព្រហ្មទណ្ឌកម្ពុជា "នៅពេលទទួល បានដីកាលើកលែងការចោទប្រកាន់ ជាផលវិបាកនៃបណ្តឹងឧទ្ធរណ៍ណាមួយដែលបានប្តឹងដោយ អយ្យការ ឬដើមបណ្តឹងរដ្ឋប្បវេណី សភាស៊ើបសួរត្រូវស៊ើបអង្កេតរឿងក្តីនោះ ដោយខ្លួនឯង"[16]។ ចំណុចនេះប្រកាន់យកតាមការអនុវត្តជាអន្តរជាតិ ដែលក្នុងស្ថានភាពពាក់ព័ន្ធនឹងសេចក្តីសម្រេច ឆន្ទានុសិទ្ធិដែលផ្អែកលើកំហុសឆ្គងផ្នែកច្បាប់ឬអង្គហេតុ អង្គជំនុំជម្រះជាអ្នកពិនិត្យបណ្តឹងឧទ្ធរណ៍

---

13 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា។

14 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានកែប្រែនៅថ្ងៃទី១៦ មករា ២០១៥។

15 សំណុំរឿង០០១-**D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច, ៥ ធ្នូ ២០០៨, កថាខណ្ឌ ៤០ ("សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះ ស្រាយ")។

16 សំណុំរឿង០០១-**D99/3/42** សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៤២។

"អាចដាក់ការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឯង ជំនួសអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើខ្លួនយល់ថាសមស្របសម្រាប់ធ្វើដូច្នេះ"[17]។

១០. តាមរបៀបផ្សេងពីនេះ អង្គបុរេជំនុំជម្រះមានអំណាចជាប់មកតាមខ្លួន ក្នុងការបញ្ជូនដីកាដំណោះស្រាយត្រឡប់ទៅ សចស វិញដើម្បីឲ្យធ្វើការវាយតម្លៃដោយផ្អែកលើច្បាប់ និងអង្គហេតុដែលត្រឹមត្រូវ[18]។ អង្គបុរេជំនុំជម្រះបានសម្រេចថា សេចក្តីសម្រេចមួយដែលបានផ្អែកលើ "ការបកស្រាយមិនត្រឹមត្រូវនៃច្បាប់គ្រប់គ្រង" "ការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងជាក់ស្តែងចំពោះអង្គហេតុ" ឬ "ការរំលោភឆន្ទានុសិទ្ធិរបស់ សចស" គឺជា "ទទ្ធីករណ៍ទាំងបី [...] ដែលអង្គបុរេជំនុំជម្រះអាចបញ្ជូនសេចក្តីសម្រេចត្រឡប់ទៅ សចស ដើម្បីធ្វើការពិចារណាឡើងវិញបាន"[19]។ ធ្វើដូច្នេះ គឺជាការអនុវត្តនៅ អ.វ.ត.ក[20]។ ទោះបីជាក្នុងស្ថានភាពដែលអង្គបុរេជំនុំជម្រះខកខានមិនបានសម្រេចជា

---

[17] *រដ្ឋអាជ្ញា ទល់នឹង* *Sefer Halilović*, IT_01-48-AR73.2, ICTY, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការសួរចម្លើយជនជាប់ចោទពីតារាងបញ្ជីឈ្មោះឯកសារដ៏វែង, ១៩ សីហា ២០០៥, កថាខណ្ឌ ៦៤ ("សាលដីកាបន្ទាន់បង្ខំក្នុងរឿងក្តី *Halilović*")។

[18] សំណុំរឿង០០២-**D300/1/7** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284, ២៨ កក្កដា ២០១០, កថាខណ្ឌ១៩, ២៦ *យោងទៅរក* ឯកសារ **D300/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើសុំ D153, D172, D173, D174, D178 និង D284, ១៥ មិថុនា ២០១០។ សំណុំរឿង០០២-**D365/2/17** សាលដីកាជាសាធារណៈស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្ម, ២៧ កញ្ញា ២០១០, កថាខណ្ឌ ៦៧, ៨១។

[19] សំណុំរឿង០០២-**D310/1/3** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ, ២១ កក្កដា ២០១០, កថាខណ្ឌ ១៥-១៦។

[20] សំណុំរឿង០០២-**D300/1/7** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការណែនាំឱ្យពិចារណាឡើងវិញលើសំណើសុំ D153, D172, D173, D174, D178 និង D284, ២៨ កក្កដា ២០១០, កថាខណ្ឌ១៩, ២៦ *យោងទៅរក* ឯកសារ **D300/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើសុំ D153, D172, D173, D174, D178 និង D284, ១៥ មិថុនា ២០១០។ សំណុំរឿង០០២-**D310/1/3** [កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបការដោយបង្ខំ, ២១ កក្កដា ២០១០, កថាខណ្ឌ ១៥-១៦។ សំណុំរឿង០០២-

ឯកច្ឆន្ទលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចឆន្ទានុសិទ្ធិក៏ដោយ ក៏ចៅក្រមអង្គបុរេជំនុំជម្រះបានថ្លែងថាពួកគាត់នឹង "បញ្ជូនបញ្ហានេះត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញដើម្បីសម្រេចលើអង្គសេចក្តី [...] ដោយមានការគិតគូរទៅលើការពិចារណាអំពីបទដ្ឋានអន្តរជាតិ" ខណៈមានការកត់សំគាល់ថា "សម្រាប់សហចៅក្រមស៊ើបអង្កេតនៅតែអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីពិចារណាឡើងវិញ" ក្នុងស្ថានភាពដូច្នេះ[21]។

១១. ជាថ្មីម្តងទៀតអំណាចនេះស្របតាមអ្វីដែលបានអនុវត្តក្នុងយុត្តសាស្ត្រអន្តរជាតិ[22]។ ជាឧទាហរណ៍នៅក្នុងរឿងក្តី*Ngudjolo* នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ("ICC") អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានច្រានចោលសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលទ្ធភាពរបស់រដ្ឋអាជ្ញាក្នុងការចូលពិនិត្យកំណត់ហេតុអកម្មនៃកិច្ចសន្ទនាតាមទូរស័ព្ទរបស់ជនជាប់ចោទ ពីមន្ទីរឃុំឃាំងរបស់តុលាការ ICC ទោះបីជាបានរកឃើញថា ព័ត៌មានដែលគេបានតាមដាននោះនឹងត្រូវដកទុក ឬបង្ហាញ គឺជាបញ្ហាមួយសម្រាប់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ[23]។

---

**D365/2/17** សាលដីកាជាសាធារណៈស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំនុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្ម, ២៧ កញ្ញា ២០១០, កថាខណ្ឌ ៦៧, ៨១។

21 សំណុំរឿង០០៣-**D26/1/3** [កោសលុប] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី", ១៥ វិច្ឆិកា ២០១១, មតិយោប់របស់ចៅក្រម Lahuis និង Downing, កថាខណ្ឌ ២០។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D11/3/4/2** [កោសលុប] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[កោសលុប], ១៣ កុម្ភៈ ២០១៣, មតិយោបល់របស់ចៅក្រម Chung និង Downing, កថាខណ្ឌ ៣៨។

22 *សូមមើល ជាឧទាហរណ៍* សាលដីកាបន្ទាន់បន្ទំក្នុងរឿងក្តី *Halilović*, កថាខណ្ឌ ៦៤។ *Jean Uwinkindi ទល់នឹង រដ្ឋអាជ្ញា*, ICTR-01-75-AR72(C), ICTR, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធញត្តិចោទប្រកាន់អំពីវិការៈនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ១៦ ធ្នូ ២០១១, កថាខណ្ឌ ៥៥។ *រដ្ឋអាជ្ញា ទល់នឹង Edouard Karemera និងគូគន*., ICTR-98-44-AR73, ICTR, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី៨ តុលា ២០០៣ ដែលបដិសេធសំណើសុំដាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានធ្វើវិសោធនកម្ម, ១៩ ធ្នូ ២០០៣, កថាខណ្ឌ ៣២។

23 *រដ្ឋអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui*, ICC-01/04-01/07 OA 9, ICC, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើ ១២០០ របស់រដ្ឋអាជ្ញាសុំការហាមឃាត់

អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC បានរកឃើញថា "ការច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់រដ្ឋអាជ្ញាសុំចូលពិនិត្យកំណត់ហេតុ ត្រូវបានធ្វើឡើងដោយផ្អែកលើការកំណត់ខុសឆ្គងមួយចំពោះភាពអាចទទួលយកបាននៃព័ត៌មានជាភស្តុតាង និងថាបើដូច្នេះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង រងផលប៉ះពាល់ជាក់ស្តែងពីកំហុសផ្នែកច្បាប់"[24]។ ដោយហេតុថាការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើសុំសិទ្ធិចូលពិនិត្យមើលព័ត៌មានរបស់រដ្ឋអាជ្ញាបានពឹងផ្អែកលើការសន្មតផ្នែកច្បាប់ដែលខុសដែលថា ព័ត៌មានដូច្នេះផ្ទាល់មិនអាចទទួលយកបាននោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថា ឧបាស្រ័យសមស្របគឺត្រូវកែប្រែសេចក្តីសម្រេចនេះ និងបញ្ជូនបញ្ហានេះត្រឡប់ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើសេចក្តីសម្រេចជាថ្មីឱ្យបានត្រឹមត្រូវដោយមានការថ្លឹងថ្លែងអំពីសិទ្ធិរបស់រដ្ឋអាជ្ញា ជាមួយនឹងសិទ្ធិរបស់ជនជាប់ចោទ[25]។

## II. ឧទ្ទឹករណ៍ទី១: សចស មានកំហុសផ្នែកច្បាប់ដែលរកឃើញថា ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ត្រូវតែបានចោទប្រកាន់ដើម្បីបានក្លាយជាផ្នែកនៃដីកាដំណោះស្រាយ

១២. ទោះបីជាអះអាងថា សចស អនុវត្តតាម "ច្បាប់លុបលើសគេ" តាមរយៈការរកឃើញថា មានតែអង្គហេតុ "ដែលត្រូវបានចោទប្រកាន់"ជាផ្លូវការណ៍ប៉ុណ្ណោះ ទើបអាចនាំទៅដល់ការបញ្ជូនទៅជំនុំជម្រះក៏ដោយ[26] ក៏ អ៊ឹម ចែម មិនបានលើកយោងរឿងក្តី ឬ ប្រភពណាមួយដើម្បីគាំទ្រដល់គោលជំហររបស់ សចស លើការចោទប្រកាន់ដែលអាចជាមូលដ្ឋាននៃការបញ្ជូនទៅជំនុំជម្រះដែរ[27]។

១៣. តាមពិត ការទាមទាររបស់ អ៊ឹម ចែម ចម្លែកណាស់បើនិយាយអំពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ ក្នុងសំណុំរឿង០០១ អង្គបុរេជំនុំជម្រះនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់

---

និងវិធានវិតត្បិតប្រឆាំងនឹង Mathieu Ngudjolo ទាក់ទងនឹងការធ្វើទំនាក់ទំនងទាំងខាងក្នុង និងខាងក្រៅមន្ទីរឃុំឃាំង", ៩ ធ្នូ ២០០៩ ("សាលដីកាក្នុងរឿងក្តី *Ngudjolo*"), កថាខណ្ឌ ៤១។

[24] សាលដីកាក្នុងរឿងក្តី *Ngudjolo*", កថាខណ្ឌ ១, ៤៤។

[25] សាលដីកាក្នុងរឿងក្តី *Ngudjolo*, កថាខណ្ឌ ៥២។

[26] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ២៦-៣០។

[27] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ២៦-៣០។

សហព្រះរាជអាជ្ញា - ជាសេចក្តីសម្រេចមួយដែល អ៊ឹម ចែម ធ្លាប់យកជាសំអាងពីមុន[28] ហើយ សចស ធ្លាប់ពឹងផ្អែកនៅក្នុងដីកាដំណោះស្រាយ(សំអាងហេតុ)[29] - បានរកឃើញដូចខាងក្រោម៖

> បទទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនមាននៅក្នុងចំណោមបទចោទ ដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ជនត្រូវចោទនៅពេលចូលខ្លួនដំបូង ឬ នៅក្នុងដំណាក់កាលក្រោយៗមកទៀត ឡើយ។
>
> អង្គហេតុគាំទ្រធាតុផ្សំដែលបង្កើតឡើងជាក់លាក់ចំពោះបទល្មើសក្រោមច្បាប់ជាតិ ត្រូវបានបញ្ចូលនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតដោយសារអង្គហេតុទាំងនេះត្រូវបានគេចោទប្រកាន់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។
> [...]
>
> ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បទទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុនក្រោមច្បាប់ជាតិ អាចបន្ថែមនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន យោងតាមការទាញអំណះអំណាងខាងលើ[30]។

១៤. ថ្វីបើត្រូវដោះស្រាយអំពីការកំណត់បទចោទក៏ដោយ ក៏អង្គបុរេជំនុំជម្រះបានរកឃើញថាបទល្មើសដែល "មិនត្រូវបានចោទប្រកាន់"ជាផ្លូវការដែលមិនបានបញ្ចូលក្នុងដីកាដំណោះស្រាយ - អាចត្រូវបានបញ្ចូលក្នុងដីកាដំណោះស្រាយលើបណ្តឹងឧទ្ធរណ៍បាន ដោយសារថាការចោទប្រកាន់ផ្អែកអង្គហេតុជាមូលដ្ឋាន ត្រូវបានដាក់បញ្ចូលក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញារួចហើយ។ អង្គបុរេជំនុំជម្រះមិនបានរកឃើញថា អវត្តមាននៃ "ការចោទប្រកាន់"ជាផ្លូវការបានរឹតត្បិតដល់ការដាក់បញ្ចូលបទល្មើសនានានៅក្នុងដីកាដំណោះស្រាយនោះទេ ឱ្យតែ សចស ត្រូវបានប្តឹងយ៉ាងត្រឹមត្រូវអំពីអង្គហេតុគាំទ្រនានា។

១៥. អ៊ឹម ចែម បានលើកយោងពីមុន[31]នូវសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលរៀបរាប់អំពីដីកាដំណោះស្រាយថាជា "សេចក្តីសម្រេចមួយដែលសន្និដ្ឋានលើ *កិច្ចស៊ើបសួរទាំងមូល*"[32]។ សេចក្តី

---

[28] **D293** សំណើររបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបំភ្លឺលើបញ្ហាផ្លូវច្បាប់ដែលអាចនឹងកើតមាននៅពេលចេញដីកាដំណោះស្រាយ ទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត, ២៦ មករា ២០១៦, កំណត់សំគាល់ជើងទំព័រ ៣៧។

[29] **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ ៤៤, ៤៥, ៤៩, ៥០។

[30] **D99/3/42** សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១០៤-១០៥, ១០៧។

សម្រេចរបស់អង្គបុរេជំនុំជម្រះដដែលនេះបានប្រកាសថា ដីកាដំណោះស្រាយ "មានការសន្និដ្ឋានខុសៗគ្នាអំពីអង្គហេតុនិងច្បាប់ទាក់ទងនឹង*កិច្ចទាំងអស់ដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរ*"[33]។ អង្គបុរេជំនុំជម្រះបានសម្រេចបន្ថែមទៀតថា "ដីកាដំណោះស្រាយ គឺជាសេចក្ដីសម្រេចដែលសហចៅក្រមស៊ើបអង្កេតសន្និដ្ឋានបិទកិច្ចស៊ើបសួររបស់ខ្លួន។ អនុលោមតាមវិធាន ៦៧(៣) និង(៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត*ត្រូវសម្រេចលើកិច្ចដែលពួកគាត់ត្រូវបានស្នើឲ្យស៊ើបសួរ*"[34]។

១៦. អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០១ បានវាយតម្លៃលើបទដ្ឋាននៃការត្រួតពិនិត្យដីកាដំណោះស្រាយ[35]។ ពេលធ្វើសេចក្ដីសម្អិតអំពីបរិវេណ/ព្រំដែននៃកិច្ចស៊ើបសួរ និងខ្លឹមសារនៃដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះមិនបានធ្វើសេចក្ដីយោងទៅរកដំណើរការនៃ "ការចោទប្រកាន់"ជាផ្លូវការ និងមិនបានផ្ដល់សញ្ញាណាមួយថា ខ្លួនបានមើលឃើញថាវាអាចអនុញ្ញាតបានសម្រាប់ដីកាដំណោះស្រាយដើម្បីធ្វើមិនដឹងមិនឮចំពោះអង្គហេតុនានាអំពីឧក្រិដ្ឋកម្មដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលមិន "ចោទប្រកាន់"នោះទេ[36]។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបានធ្វើសេចក្ដីយោងទៅរក ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា និងកាតព្វកិច្ចរបស់ សចស ដើម្បី (i) ស៊ើបអង្កេតលើការចោទប្រកាន់ដែលមាននៅក្នុងនោះ និង (ii) ធ្វើការកំណត់លើការចោទប្រកាន់ផ្នែកអង្គហេតុដូច្នេះទាំងអស់ នៅក្នុងដីកាដំណោះស្រាយ[37]។

---

31 **D293** សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបំភ្លឺលើបញ្ហាផ្លូវច្បាប់ដែលអាចនឹងកើតមាននៅពេលចេញដីកាដំណោះស្រាយ ទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត, ២៦ មករា ២០១៦, កំណត់សំគាល់ជើងទំព័រ ៣១។

32 **D99/3/42** សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២៩ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

33 **D99/3/42** សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២៩ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

34 **D99/3/42** សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៣ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

35 **D99/3/42** សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣២-៣៩។

36 **D99/3/42** សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣២-៣៩។

37 **D99/3/42** សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣២-៣៩។

១៧. អង្គបុរេជំនុំជម្រះ គឺច្បាស់លាស់ណាស់ដោយបានសម្រេចទាំងគ្មានមន្ទិលថា ដីកាដំណោះស្រាយត្រូវតែមានការសម្រេចលើគ្រប់អង្គហេតុទាំងអស់ដែល សចស ត្រូវបានប្តឹងយ៉ាងត្រឹមត្រូវ៖

> វិធាន ៦៧ នៃវិធានផ្ទៃក្នុង បង្គាប់ថា នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត *ត្រូវតែសម្រេចលើអង្គហេតុទាំងអស់ ប៉ុន្តែអង្គហេតុទាំងអស់នោះ គឺជាផ្នែកមួយនៃកិច្ចស៊ើបសួររបស់ខ្លួន។* សហចៅក្រមស៊ើបអង្កេត អាចច្រានចោលអង្គហេតុទាំងនោះ ដោយផ្អែកលើហេតុផលណាមួយក្នុងចំណោមហេតុផលនានា ដែលបានលើកឡើងនៅក្នុងវាក្យខណ្ឌទី៣ នៃវិធានផ្ទៃក្នុង ឬក៏បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ដោយសំអាងលើអំពើទាំងនេះ[38]។

១៨. ផ្ទុយនឹងការអះអាងរបស់ អ៊ឹម ចែម គ្មានសញ្ញាបង្ហាញណាមួយនៅក្នុងសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរថា "វិសាលភាពនៃអង្គហេតុពាក់ព័ន្ធ និងភាពវិនិយភាព នឹងត្រូវបានសម្រេចតាម ការជូនដំណឹងអំពីបទចោទ ទេ ហើយក៏មិនមែនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែរ[39]។ តាមពិត សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ បានកត់សំគាល់ថា គិតត្រឹមខែកក្កដា ឆ្នាំ២០១៥ - នៅពេលមានសំណើសុំសារណាពីភាគីនានា ស្តីពីថាតើ អ៊ឹម ចែម បានបំពេញតាមលក្ខខណ្ឌតម្រូវខាងផ្នែកយុត្តាធិការរបស់ អ.វ.ត.ក ដែរឬអត់នោះ - "ការកំណត់អំពីតួនាទីរបស់ អ៊ឹម ចែម ទាក់ទងទៅនឹង *ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ដោយ សពអ* គឺជិតដល់ពេលបញ្ចប់ហើយ"[40]។ អ្វីដែលមានក្នុងសំណើសុំសារណាពីភាគីនានាស្តីពីយុត្តាធិការនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានថ្លែងថា "បញ្ហាពាក់ព័ន្ធថាតើជនត្រូវចោទមានគុណវុឌ្ឍិជាជនម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ឬអត់នោះ គឺជាបញ្ហាដែលនឹងត្រូវកំណត់នៅចុងបញ្ចប់នៃកិច្ចស៊ើបសួរ តាមស្មារតីនៃ*ភស្តុតាងទាំងអស់* ដែលប្រមូលបាន"[41]។ ជាការបន្ថែម សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានសម្រេចនៅក្នុងករណីដាច់ដោយឡែកមួយថា ការធ្វើសេចក្តីសម្រេចមួយលើបញ្ហាយុត្តាធិការបុគ្គលមុនពេលបិទកិច្ចស៊ើបសួរ យ៉ាងដូច្នេះថា៖

---

38 **D99/3/42** សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៧ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

39 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣១។

40 **D285** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម, ១៨ ធ្នូ ២០១៥, កថាខណ្ឌ ៣ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

41 **D251** សំណើសុំដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ ស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត", ២៤ កក្កដា ២០១៥, កថាខណ្ឌ ៥។

"នឹងមិនផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាអាចត្រួតពិនិត្យលទ្ធផលស៊ើបអង្កេតពេញលេញទៅលើបញ្ហាយុត្តាធិការទេ ដូច្នេះនឹងធ្វើឲ្យសហព្រះរាជអាជ្ញា បាត់បង់ឱកាសវាយតម្លៃភ័ស្តុតាងអំពីយុត្តាធិការបុគ្គលនៅក្នុងសំណុំរឿង ដើម្បីរៀបចំសំណើដាក់ជូនសហចៅក្រមស៊ើបអង្កេតតាមវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង ថាតើត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់[42]។

១៩. ច្បាស់លាស់ថា គ្មានចេតនានៅក្នុងករណីនេះដើម្បីកម្រិតការចោទប្រកាន់ផ្នែកអង្គហេតុ ដែលការសម្រេចជាចុងក្រោយនៅក្នុងដីកាដំណោះស្រាយ នឹងត្រូវពឹងផ្អែកតែទៅលើការចោទប្រកាន់ដែលត្រូវបាន "ចោទប្រកាន់"[43]តែប៉ុណ្ណោះ នោះទេ។

*(i) ការកំណត់ចរិកលក្ខណៈខុសរបស់ អ៊ឹម ចែម អំពីអ្វីដែលដីកាដំណោះស្រាយត្រូវមាន*

២០. នៅក្នុងចម្លើយតបរបស់គាត់ អ៊ឹម ចែម ទទួលស្គាល់ថា "ដីកាដំណោះស្រាយមិនគ្របដណ្តប់សេចក្តីពិចារណាដែលមានសំអាងហេតុ លើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ អ៊ឹម ចែម ដូចបានចោទប្រកាន់ ទេ"[44]។ យ៉ាងណាមិញ ចំណុចនេះគឺជាកំហុសផ្នែកច្បាប់មួយ ដោយសារអង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងច្បាស់ថា ដីកាដំណោះស្រាយត្រូវមានសំអាងហេតុសម្រាប់ដីកាសម្រេចរបស់ សចស ថាតើ ត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយដែលពួកគាត់ត្រូវបានប្តឹងដោយសហព្រះរាជអាជ្ញា យ៉ាងដូច្នេះថា៖

"សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការច្រានចោលអំពើទាំងឡាយ ឬ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះត្រូវផ្តល់សំអាងហេតុ ដូចមានចែងយ៉ាងច្បាស់នៅក្នុងវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះ ក៏រំលឹកផងដែរថា វាគឺជាបទដ្ឋានអន្តរជាតិដែលសេចក្តីសម្រេចរបស់តុលាការ ទាមទារឲ្យមានការផ្តល់សំអាងហេតុ"[45]។

---

42 **D185/1** [កោសលុប] ដីកាសម្រេចស្តីពីញត្តិរបស់ស្នើសុំមោឃភាពកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន៧៦ នៃវិធានផ្ទៃក្នុង, ២២ មេសា ២០១៤, កថាខណ្ឌ ២៨។

43 *ផ្ទុយ* **D308/3/1/1** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ២៤-៣៩។

44 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៧៥។

45 សំណុំរឿង០០១-**D99/3/42** សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៨។

២១. ការទាមទាររបស់ អ៊ឹម ចែម ដែលថា "កាតព្វកិច្ច"របស់ សចស ដើម្បីធ្វើកំណត់ក្នុងដីកាដំណោះស្រាយ "ទាក់ទងនឹងអង្គហេតុនិមួយៗដែលពួកគាត់ត្រូវបានប្ដឹងយ៉ាងត្រឹមត្រូវ"[46] ដែលបាន "កើតឡើងតែនៅពេលណាដែលយុត្តិធិការត្រូវបានកំណត់"[47]នោះ គឺច្បាស់ណាស់ថា មិនត្រឹមត្រូវទេ។ ការវាយតម្លៃយុត្តាធិការដែលត្រឹមត្រូវនិងជឿជាក់បាន អាចធ្វើទៅបាន*តែ* នៅពេលណាដែលអង្គហេតុទាំងអស់ដែលពាក់ព័ន្ធនឹងការកំណត់ពីបញ្ហាយុត្តាធិការ ត្រូវបានវាយតម្លៃប៉ុណ្ណោះ។ តក្កវិជ្ជាដែលមានកំហុសរបស់ អ៊ឹម ចែម ឲ្យដឹងថា សេចក្ដីសម្រេចស្ដីពីយុត្តាធិការអាចនឹងត្រូវបានធ្វើឡើងដោយពុំចាំបាច់ធ្វើការកំណត់ចំពោះអង្គហេតុដែលពាក់ព័ន្ធ ដែលជាភ័ស្តុតាងចាំបាច់សម្រាប់ការបញ្ជាក់ចំពោះការកំណត់នោះទេ។ នៅក្រោមការបកស្រាយដែលមានកំហុសរបស់ អ៊ឹម ចែម ស្ដីពីនីតិវិធី អ.វ.ត.ក សចស អាចច្រានចោលអង្គហេតុទាំងឡាយណាដែលប្ដឹងមកខ្លួនដោយគ្មានការចេញសេចក្ដីសម្រេចដែលមានសំអាងហេតុ ងាយៗដោយគ្រាន់តែមិន"ចោទប្រកាន់" ចំពោះឧក្រិដ្ឋកម្មទាក់ទងនឹងអង្គហេតុនោះជាការស្រេច។ ការណ៍នេះជាការរំលោភគោលការជាមូលដ្ឋានបំផុតមួយនៃនីត្យានុកូលភាព និងផ្ទុយពីសារណារបស់ អ៊ឹម ចែម ខ្លួនឯងផ្ទាល់[48]។ ក្នុងពេលថ្មីៗបំផុត ក្នុងពេលធ្វើការជំទាស់នឹងការធ្វើចំណាត់ថ្នាក់ឡើងវិញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ជាសាធារណ: អ៊ឹម ចែម បានលើកយោងយុត្តិសាស្ត្រសម្រាប់ជាសេចក្ដីស្នើថា "ប្រសិនបើចៅក្រមមិនផ្ដល់ជូនតាមសំណើរបស់សាម៉ីជន គាត់ត្រូវតែផ្ដល់សេចក្ដីសម្រេចដែលមានសំអាងហេតុ ដែលសេចក្ដីសម្រេចនេះជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខសភាស៊ើបសួរ" ហើយ "ប្រសិនបើសភាស៊ើបសួរមិនផ្ដល់តាមសំណើសុំរបស់សាម៉ីជន នោះសភាស៊ើបសួរត្រូវតែចេញសេចក្ដីសម្រេចដែលមានសំអាងហេតុ"[49]។

២២. អ៊ឹម ចែម ទាមទារទាំងមានកំហុសបន្ថែមទៀតថា "ការរកឃើញថា អ.វ.ត.ក កង្វះយុត្តាធិការលើ អ៊ឹម ចែម *បានច្រានចោលការរកឃើញណាមួយ* ពាក់ព័ន្ធនឹងភរនីយភាពនៃការទទួលខុសត្រូវរបស់

---

[46] សំណុំរឿង០០២-**D198/1** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ, ២០ វិច្ឆិកា ២០០៩, កថាខណ្ឌ ១០។

[47] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ២៩។

[48] *សូមមើល* **D204** ញត្តិរបស់ អ៊ឹម ចែម ស្នើសុំឲ្យមានការស្រាយបំភ្លឺ ទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត, ២៥ កក្កដា ២០១៤, កថាខណ្ឌ ១៤, កំណត់សំគាល់ជើងទំព័រ ៣២។

[49] **D309/2/1/3** ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សម្អាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ), ៤ កញ្ញា ២០១៧, កំណត់សំគាល់ជើងទំព័រ ៤៨។

គាត់ចំពោះឧក្រិដ្ឋកម្មនានា”[50] និង “ដកចេញនូវភាពចាំបាច់និងកាតព្វកិច្ចក្នុងការធ្វើសេចក្តីសម្រេចណាមួយទៅលើ 'អង្គហេតុនិមួយៗដែលពួកគាត់ [សចស] ត្រូវបានថ្លឹងយ៉ាងត្រឹមត្រូវ ទោះជាតាមរយៈការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះឬលើកលែងការចោទប្រកាន់ក៏ដោយ'”[51]។ បន្ទាប់ពីមានតក្កាវិជ្ជារបស់ អ៊ឹម ចែម សចស មិនតម្រូវឱ្យធ្វើរបកគំហើញផ្នែកអង្គហេតុណាមួយលើការចោទប្រកាន់ណាមួយឡើយ ប្រសិនបើការសន្និដ្ឋានចំពោះករណីនេះថា លក្ខខណ្ឌតម្រូវចំពោះយុត្តាធិការបុគ្គលមិនត្រូវបានបំពេញ។ ដូច្នេះ ដីកាដំណោះស្រាយរបស់ សចស (ផ្នែកសម្រេចសេចក្តី)[52] តែប៉ុណ្ណោះ គឺជាការគ្រប់គ្រាន់ហើយសម្រាប់លក្ខខណ្ឌតម្រូវខ្ពស់បំផុតចំពោះករណីនេះ។ ជាលទ្ធផលគឺថា គ្មានបណ្តឹងឧទ្ធរណ៍ណាមួយអាចនឹងត្រូវធ្វើឡើងយ៉ាងមានប្រសិទ្ធភាព ប្រឆាំងទៅនឹងសេចក្តីសម្រេចច្រានចោលរឿងក្តីណាមួយឡើយ ដោយផ្អែកលើយុត្តាធិការបុគ្គល។ នេះគឺជាគោលជំហរផ្លូវច្បាប់ដ៏គួរឱ្យស្អប់ខ្ពើមមួយ - ដែលស្វែងរកការបដិសេធឱកាសប្តឹងឧទ្ធរណ៍របស់ភាគីដែលរងផលប៉ះពាល់ ប្រឆាំងនឹងសេចក្តីសម្រេចដែលអនុគ្រោះចំពោះខ្លួន។

២៣. លើសពីនេះ គោលជំហររបស់ អ៊ឹម ចែម ត្រូវបានជំទាស់ដោយយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជំម្រះដែលធ្លាប់បដិសេធការរកឃើញពីមុនរបស់ សចស នៅក្នុងដីកាដំណោះស្រាយមួយដែលមានមូលដ្ឋានថា “សហចៅក្រមស៊ើបសង្កេតខកខានមិនបាន 'លើកអំពីសំអាងហេតុសម្រាប់សេចក្តីសម្រេចនោះទេ' ហេតុដូច្នេះ គាត់មិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង និងបទដ្ឋានអន្តរជាតិទេ”[53]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល ក្នុងកិច្ចពិភាក្សារបស់ខ្លួននៅក្នុងសេចក្តីសម្រេច ដែលមានលក្ខណៈជាឆន្ទានុសិទ្ធិស្តីពីយុត្តាធិការបុគ្គល បានថ្លែងថាសេចក្តីសម្រេចដូច្នេះ អាចត្រូវបានបដិសេធតាមរយៈការបង្ហាញនូវអំពើទុច្ចរិត ឬសេចក្តីសម្រេចជាអាជីពមិនត្រឹមត្រូវក៏ដោយ[54] - ប៉ុន្តែបញ្ហាប្រឈមដូច្នេះនឹងមិនអាចទៅរួចឡើយប្រសិនបើ សចស អាចច្រានចោលអង្គហេតុនានាដោយពុំចាំបាច់ផ្តល់សំអាងហេតុណាមួយនោះ។ អំណះអំណាងរបស់ អ៊ឹម ចែម ក៏ផ្ទុយនឹងការអនុវត្តជាអន្តរជាតិផងដែរ។ ជាឧទាហរណ៍ ពេលធ្វើការសម្រេច*មិន* តម្កល់

---

[50] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ១៩ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

[51] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣០។

[52] **D308** ដីកាដំណោះស្រាយ(ផ្នែកសម្រេចសេចក្តី), ២២ កុម្ភៈ ២០១៧។

[53] **D99/3/42** សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៥៧។ *សូមមើល* ផងដែរ កថាខណ្ឌ ១១៥។

[54] សំណុំរឿង០០១-**F28** សាលដីកាសម្រេចលើបណ្តឹងសារទុក្ខក្នុងសំណុំរឿង០០១, ៣ កុម្ភៈ ២០១២, កថាខណ្ឌ ៨០។

បទចោទប្រឆាំងជនសង្ស័យជាច្រើន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC បានពិចារណាយ៉ាងលម្អិតអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលជនសង្ស័យម្នាក់ៗ[55]។

២៤. ជាការគួរកត់សំគាល់ថា អ៊ឹម ចែម ពឹងផ្អែកលើការអះអាងដែលមានកំហុសថា ឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់ មិនអាចត្រូវបានពិចារណានៅក្នុងដីកាដំណោះស្រាយឡើយ ខណៈពុំមានការប៉ុនប៉ងណាមួយត្រូវបានធ្វើឡើងដើម្បីជាយុត្តិកម្មចំពោះការខកខានរបស់ សចស មិនចោទប្រកាន់ឧក្រិដ្ឋកម្មនានាដោយផ្អែកលើអង្គហេតុទាំងនេះ[56]។ ចំណុចនេះ បានធ្វើឲ្យ អ៊ឹម ចែម គេចផុតពីការសន្និដ្ឋានមួយយ៉ាងច្បាស់លាស់ថាគេមិនអាចកំណត់ពីរបៀបថាតើការវាយតម្លៃរបស់ សចស ស្ដីពីយុត្តាធិការបុគ្គលនឹងត្រូវបានផ្លាស់ប្ដូរទៅជាយ៉ាងណានោះទេ ប្រសិនបើការចោទប្រកាន់ទាំងអស់ដែល សចស ត្រូវបានប្ដឹងនោះ ត្រូវបានពិចារណា។

### *(ii) ចម្លើយតបរបស់ អ៊ឹម ចែម ផ្ទុយពីសារណាមុនៗរបស់ខ្លួន*

២៥. ផ្ទុយពីការទាមទាររបស់ អ៊ឹម ចែម[57] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ គឺជាលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៅក្នុងដំណាក់កាលជាក់លាក់នៃកិច្ចស៊ើបសួរនៅ អ.វ.ត.ក ទោះក្នុងមធ្យោបាយណាក៏ដោយ មិនអាចជួយសម្រាលដល់ភារកិច្ចរបស់ សចស ក្នុងការវាយតម្លៃលើអង្គហេតុទាំងអស់ដែលប្ដឹងទៅពួកគាត់នោះទេ ។ ដូចសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានប្រាប់មេធាវី អ៊ឹម ចែម ដែរ - ដែលបានស្នើសុំសិទ្ធិចូលពិនិត្យមើលសំណុំរឿងដោយផ្អែកលើមូលដ្ឋានថា អ៊ឹម ចែម គួរបានពិចារណាថាជាជនត្រូវចោទ ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា[58] - "អ្នកអាចត្រូវបានផ្ដល់សិទ្ធិចូលពិនិត្យមើលសំណុំរឿងបាន តែក្នុងករណី

---

[55] *សូមមើល រដ្ឋអាជ្ញា ទល់នឹង William Samoei Ruto, Henry Kiprono Kosgey និង Joshua Arap Sang*, ICC-01/09-01/11, ICC, សេចក្តីសម្រេចលើការបញ្ជាក់ចំពោះបទចោទ អនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម, ២៣ មករា ២០១២, កថាខណ្ឌ ២៨២-៣០០។ *រដ្ឋអាជ្ញា ទល់នឹង Callixte Mbarishumana*, ICC-01/04-01/10, ICC, សេចក្តីសម្រេចលើការបញ្ជាក់ចំពោះបទចោទ, ១៦ ធ្នូ ២០១១, កថាខណ្ឌ ២៩១-៣៤០ និង *សូមមើល រដ្ឋអាជ្ញា ទល់នឹង Bahar Idriss Abu Garda*, សេចក្តីសម្រេចលើការបញ្ជាក់ចំពោះបទចោទ, ICC-02/05-02/09, ICC, ៨ កុម្ភៈ ២០១០, កថាខណ្ឌ ១៥៨-២៣២។

[56] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ១០៥។

[57] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣១។

[58] **D201** សំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង, ២១ ឧសភា ២០១៤, កថាខណ្ឌ ១១-១៣, ១៥ ("សំណើរបស់ អ៊ឹម ចែម សុំចូលពិនិត្យមើលសំណុំរឿង")។

ដែលកូនក្ដីរបស់អ្នកត្រូវបាន*ចោទប្រកាន់ជាផ្លូវការ* ប៉ុណ្ណោះ”[59]។ គោលជំហររបស់ អ៊ឹម ចែម ដែលថា គាត់គ្មានមូលហេតុដែលត្រូវព្រួយបារម្ភទាក់ទងនឹងអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាល់តែ និងរហូតដល់ពេលរូបគាត់ត្រូវបានចោទប្រកាន់នោះ គឺផ្ទុយទៅនឹងសារណាមុនៗរបស់គាត់ទាក់ទងនឹងដំណើរការនៃ “ការចោទប្រកាន់”។ នៅពេលស្វែងរកសិទ្ធិចូលពិនិត្យមើលសំណុំរឿងមុនសេចក្ដីជូនដំណឹងអំពីបទចោទ អ៊ឹម ចែម បានទាមទារថា “គាត់គឺជាជនត្រូវចោទដោយសារ 'គាត់ជាកម្មវត្ថុនៃការចោទប្រកាន់នៅក្នុង...[សំណុំរឿង០០៤] នៅក្នុងចិរវេលាចន្លោះរវាងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬការលើកលែងការចោទប្រកាន់'”[60]។ អ៊ឹម ចែម បានពឹងផ្អែកលើករណីយុត្តិសាស្ត្របារាំង ដើម្បីឲ្យវាកាន់តែមានប្រសិទ្ធិភាព ថា “បុគ្គលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវបានចាត់ទុកដោយស្វ័យប្រវត្តិថា ត្រូវបានចោទប្រកាន់”[61]។

២៦. អ៊ឹម ចែម ក៏បានកំណត់ចរិកលក្ខណៈខុសចំពោះសំណើរបស់ខ្លួនសុំដាក់ប្រតិចារឹកសំណុំរឿង០០២ ទាក់ទងនឹងការដ្ឋានទំនប់អាងត្រពាំងថ្ម[62]ទៅក្នុងសំណុំរឿងនេះផងដែរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា បានធ្វើការចោទប្រកាន់មួយចំនួនអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅទីតាំងឧក្រិដ្ឋកម្មនេះ ប៉ុន្តែ សចស មិនដែលដាក់បញ្ចូលទីតាំងនេះនៅក្នុងសេចក្ដីជូនដំណឹងអំពី ទេ។ ឥឡូវនេះ អ៊ឹម ចែម ទាមទារថា សំណើនេះមិនមែនជាសំណើសុំបំពេញកិច្ចស៊ើបសួរទេ[63]។ យ៉ាងណាមិញ អង្គបុរេជំនុំជម្រះ - ដូចបានកត់សំគាល់ដោយ សចស - បានសម្រេចថា “សំណើសុំការសម្រេចដើម្បីដាក់សម្ភារទៅក្នុងសំណុំរឿង គឺជាសំណើមួយអនុលោមតាមវិធាន ៥៥(១០) ដោយសារវាតម្រូវឲ្យ សចស វាយតម្លៃលើសម្ភារនោះរកភាពពាក់ព័ន្ធរបស់វាទៅនឹងកិច្ចស៊ើបសួរនិងមានគោលបំណងរបស់វាដើម្បីកំណត់អំពីការពិត”[64]។ វិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង

---

59 **D201/1** ដីកាសម្រេចលើសំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង, ២៦ មិថុនា ២០១៤, 00997338 (សង្កត់ន័យត្រង់អក្សរទ្រេត)។

60 **D201** សំណើរបស់ អ៊ឹម ចែម សុំចូលពិនិត្យមើលសំណុំរឿង, កថាខណ្ឌ ១២។

61 **D201** សំណើរបស់ អ៊ឹម ចែម សុំចូលពិនិត្យមើលសំណុំរឿង, កថាខណ្ឌ ១៤។

62 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣២។

63 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣២។

64 **D300/2** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤/១, ៤ មីនា ២០១៦, កថាខណ្ឌ ៩ យោង សំណុំរឿង០០២-**D365/2/17** សាលដីកាស្ដីពីការពិចារណាឡើងវិញ ទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់

ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា "នៅគ្រប់ពេលវេលានៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់កិច្ចស៊ើបសួរ"។

២៦. ជាការបន្ថែម អ៊ឹម ចែម អះអាងថា "បន្ទាប់ពីការបិទកិច្ចស៊ើបសួរនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សេចក្ដីជូនដំណឹងអំពីបទចោទ បានផ្ដល់ព័ត៌មានចុងក្រោយដល់ អ៊ឹម ចែម អំពីបទចោទ *ពិតប្រាកដ* និង ការគូសវាសច្បាស់លាស់ពីវិសាលភាពនៃការបញ្ជូនរឿងទៅជំនុំជម្រះជាសក្ដានុពលណាមួយ" ហើយ "ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មណាមួយនៅក្រៅបទចោទ ដូចបានគូសបញ្ជាក់ក្នុងសេចក្ដីជូនដំណឹងអំពីបទចោទ *លែងពាក់ព័ន្ធ ឬ កម្មវត្ថុនៃការត្រៀមរៀបចំការការពារក្ដីទៀតហើយ*"[65]។ ប៉ុន្តែចំណុចនេះគឺផ្ទុយពីសារណាមុនៗរបស់ អ៊ឹម ចែម ដែលបង្ហាញថា ក្រុមការពារក្ដីរបស់គាត់បានដឹងយ៉ាងច្បាស់ អំពីលទ្ធភាពនៃការបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះចំពោះអង្គហេតុដែលមិនបានដាក់បញ្ចូលនៅក្នុង"បទចោទ" របស់ សចស ហើយបានចាត់វិធានការផ្សេងៗដើម្បីផលប្រយោជន៍របស់គាត់ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនេះ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ២០១៦ ពីរខែក្រោយការបិទកិច្ចស៊ើបសួរ អ៊ឹម ចែម បានដាក់សំណើមួយទៅ សចស ស្នើសុំមោឃភាពកំណត់ហេតុនៃការស្ដាប់ចម្លើយដែលពាក់ព័ន្ធនឹង[66] មានជាអាទិ៍ ការដ្ឋានទំនប់អាងត្រពាំងថ្ម[67] និងមន្ទីរសន្តិសុខវត្តចំការខ្នុរ[68]។ គ្មានទីតាំងឧក្រិដ្ឋកម្មណាមួយនៃទីតាំងឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានចោទប្រកាន់ជាផ្លូវការដោយ សចស ក្នុងសេចក្ដីជូនដំណឹងអំពីបទចោទទេ។ អាស្រ័យហេតុនេះ ផ្ទុយទៅនឹងការទាមទារបច្ចុប្បន្នរបស់ អ៊ឹម ចែម ដែលថា មេធាវីការពារក្ដីរបស់គាត់គ្រាន់តែបានរៀបចំលទ្ធភាពនៃការ

---

បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម, ២០ កញ្ញា ២០១០, កថាខណ្ឌ ៤៥-៤៦។

65 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣៣ (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត)។

66 **D298** សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារិត និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន, ១៦ កុម្ភៈ ២០១៦។

67 **D298.4** ឧបសម្ព័ន្ធ គ នៃសំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារិត និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន, ១៦ កុម្ភៈ ២០១៦, EN 01204928។

68 **D298.4** ឧបសម្ព័ន្ធ គ នៃសំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារិត និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន, ១៦ កុម្ភៈ ២០១៦, EN 01204935-01204936។

បញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្មដែល "បានចោទប្រកាន់" នៅពេលបិទកិច្ចស៊ើបសួរប៉ុណ្ណោះ ប៉ុន្តែ អ៊ឹម ចែម បានស្វែងរកការធ្វើមោឃភាពលើកំណត់ហេតុនៃការស្ដាប់ចម្លើយទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលមិន "បានចោទប្រកាន់" ប៉ុន្តែ គាត់បានយល់ថាគាត់អាចនឹងត្រូវបានបញ្ជូនទៅជំនុំជម្រះដោយសារវាបានដាក់បញ្ចូលនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

២៨. អ៊ឹម ចែម បានធ្វើលើសពីនេះទៀតជាបន្តបន្ទាប់ ដោយបានបង្កើតសារណាបន្ថែមទៀត ស្ដីពីរបៀបដែលសំណុំរឿងនេះ ត្រូវដំណើរការយ៉ាងណានៅក្នុងពេលរង់ចាំដំណោះស្រាយលើសំណើសុំមោឃភាពរបស់គាត់ ដោយកត់សំគាល់ថា ប្រសិនបើកំណត់ហេតុនៃការស្ដាប់ចម្លើយត្រូវបានទុកជាមោឃៈ នោះកំណត់ហេតុទាំងនោះនឹងត្រូវ"បានដកចេញពីសំណុំរឿង ហើយសេចក្ដីសន្និដ្ឋានណាមួយដែលទាញចេញពីនោះនឹងត្រូវបានហាមឃាត់"[69] និងថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា "បើសិនជាបាននិយាយអំពីផ្នែកណាមួយដែលត្រូវបានទុកជាមោឃៈ - ក្លាយជាមោឃៈដែរ"[70]។ ហេតុដូច្នេះ អ៊ឹម ចែម បានរំពឹងទុកយ៉ាងច្បាស់ថា នៅក្រោយការបិទកិច្ចស៊ើបសួរ ការចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមិនត្រូវ "បានចោទប្រកាន់"ជាផ្លូវការ ប៉ុន្តែមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាផ្នែកនៃសំណុំរឿងសម្រាប់គោលបំណងនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និង ដីកាដំណោះស្រាយ[71]។

*(ii) អ៊ឹម ចែម បកស្រាយខុសអំពីសិទ្ធិទទួលបានការស្ដាប់សវនាការរបស់សហព្រះរាជអាជ្ញា*

២៩. អ៊ឹម ចែម បានអះអាងថា វា "ស្របទៅនឹងគោលការណ៍សមភាពក្នុងការតទល់ក្ដី" សម្រាប់សហព្រះរាជអាជ្ញា ដើម្បីកុំឲ្យមានការស្ដាប់សវនាការលើការចោទប្រកាន់ផ្នែកអង្គហេតុនានាដែលមិនមានបញ្ចូលនៅក្នុងសេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ សូម្បីតែតាមការបកស្រាយ

---

69 **D298/2/1/2** ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីពាក្យស្នើសុំរបស់អ្នកស្រីសុំមោឃភាពលើកំណត់ហេតុស្ដាប់ចម្លើយសាក្សីមួយចំនួន, ១៣ មិថុនា ២០១៦, កថាខណ្ឌ ១១។

70 **D298/2/1/2** ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីពាក្យស្នើសុំរបស់អ្នកស្រីសុំមោឃភាពលើកំណត់ហេតុស្ដាប់ចម្លើយសាក្សីមួយចំនួន, ១៣ មិថុនា ២០១៦, កថាខណ្ឌ ១១។

71 *សូមមើលផងដែរ* **D296/2** សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុស្ដាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង, ២៦ សីហា ២០១៦, កថាខណ្ឌ ១៤។

របស់គាត់ដែលថា ការចោទប្រកាន់ណាមួយដែលមិនបានដាក់បញ្ចូល ដំណើរការជាការលើកលែងការចោទប្រកាន់ដ៏មានប្រសិទ្ធិភាព[72]។

៣០. អ៊ឹម ចែម លើកឡើងយ៉ាងចម្លែកថា សិទ្ធិរបស់សហព្រះរាជអាជ្ញាត្រូវបានការពារដោយ "នីតិវិធីនៃការការពារដ៏ជាក់លាក់" ក្នុងទម្រង់ជា "សារណាឯករាជ្យដើម្បីបញ្ជាក់ជំហររបស់ខ្លួន ជាការតវ៉ាសុំឱ្យមានការកែតម្រូវនូវទម្រង់នៃការចោទប្រកាន់ ដោយរួមទាំងបញ្ចូលនូវភ័ស្តុតាងជាមូលដ្ឋានសម្រាប់ធ្វើការស្នើសុំឱ្យមានការចោទប្រកាន់បន្ថែម"[73]។ អំណះអំណាងរបស់ អ៊ឹម ចែម ខ្វះចំណុចបឋមចំនួនពីរ។ ទីមួយ សេចក្តីជូនដំណឹងអំពីបទចោទប្រកាន់មិនមែនជាដីកាសម្រេចមានសំអាងហេតុនោះទេ។ វាមិនមានការវាយតម្លៃ ឬការសម្រេចអំពីមូលហេតុដែលការចោទប្រកាន់ផ្នែកអង្គហេតុណាមួយ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ ដែលអាចត្រូវបានដកចេញពីក្នុងនោះឡើយ។ ការលើកឡើងរាក់កំផែលរបស់ អ៊ឹម ចែម អំពីការដាក់សារណាភ័ស្តុតាងដើម្បីស្វែងរកឱ្យធ្វើការកែប្រែដីកាសម្រេចមួយ ដែលក្នុងដីកានោះមិនមានការវាយតម្លៃភ័ស្តុតាង ឬសំអាងហេតុនោះ ហេតុដូច្នេះគឺមិនមានអង្គសេចក្តីនោះឡើយ។ ដីកាសម្រេចចោទប្រកាន់របស់ សចសអ មិនមែនមានន័យថាច្រានចោលអង្គហេតុពីការស៊ើបអង្កេតនោះឡើយ ដូច្នេះមិនមានដីកាសម្រេច និងមិនមានសំអាងហេតុ ដែល សពអ អាចប្តឹងឧទ្ធរណ៍បាននោះទេ[74]។ ទីពីរ សហព្រះរាជអាជ្ញា មិនបានដាក់សំណើណាមួយ "ស្នើសុំឱ្យកែតម្រូវ" បែបនេះនោះទេ ដោយសារតែរូបគាត់មិនយល់ថាវាចាំបាច់ដោយសារច្បាប់ - ដូចបានបង្ហាញខាងលើ និងនៅក្នុងបណ្តឹងឧទ្ធរណ៍- មិនតម្រូវឱ្យការចោទប្រកាន់ផ្នែកអង្គហេតុត្រូវតែ "ចោទប្រកាន់" ជាផ្លូវការ ដើម្បីឱ្យស្ថិតនៅក្រោមការបញ្ជូនខ្លួនទៅជំនុំជម្រះដែលអាចកើតមាននៅក្នុងដីកាដំណោះស្រាយនោះឡើយ។ ជាងនេះទៀត នៅពេលដែល អ៊ឹម ចែម ត្រូវបាន "ចោទប្រកាន់" សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានថ្លែងយ៉ាងជាក់

---

[72] *សូមមើល*, **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣៤។

[73] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣៥។

[74] *សូមមើលផងដែរ*, សំណុំរឿង០០៣-**D174/1/4** [កោសលុប] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវ, ២៧ មេសា ២០១៦, យោបល់របស់ចៅក្រម Beauvallet និង Baik ទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ, កថាខណ្ឌ ១៤-១៧។

លាក់ថា ការចោទប្រកាន់បន្ថែមអាចត្រូវបានដាក់បន្ថែមទៀតនៅពេលក្រោយ[75]។ មិនមានអង្គហេតុណាត្រូវបានច្រានចោលដោយដីកាសម្រេចចោទប្រកាន់នោះទេ។

*(iii) អ៊ឹម ចែម បកស្រាយខុសអំពីសិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការប្ដឹងឧទ្ធរណ៍*

៣១. អ៊ឹម ចែម អះអាងថា សហព្រះរាជអាជ្ញាគួរតែបានប្ដឹងឧទ្ធរណ៍សេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់[76] ក៏មានការខ្វះចន្លោះដូចគ្នាដែរទាក់ទងនឹងលក្ខខណ្ឌតម្រូវផ្នែកច្បាប់ជាមូលដ្ឋាន។ សេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ តាមលក្ខខណ្ឌតម្រូវនៃវិធាន៥៧ នៃវិធានផ្ទៃក្នុង គ្រាន់តែ "ត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និង ប្រាប់ជននោះអំពីបទចោទប្រកាន់"។ ចំពោះ អ៊ឹម ចែម ដែលបានលើកឡើងថា សហព្រះរាជអាជ្ញាគួរបានប្ដឹងឧទ្ធរណ៍ដីកាសម្រេច ដែលមិនមានសំអាងហេតុនោះ ដូច្នេះគឺមិនមានអង្គសេចក្ដីទាល់តែសោះ[77]។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់ អ៊ឹម ចែម ដែលថា បណ្ដឹងឧទ្ធរណ៍របស់គាត់អំពីសេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ បង្ហាញថាមិនមានឧបសគ្គដល់សហព្រះរាជអាជ្ញា "ក្នុងការបង្ហាញហេតុផលណាមួយដែលទាក់ទងនឹងភ័ស្ដុតាង" ការកំណត់លក្ខខណ្ឌដែលអាចអនុវត្តបានសម្រាប់ការចោទប្រកាន់ ឬ "ភាពសមស្របនៃការចោទប្រកាន់បន្ថែម"[78]នោះ គឺមិនមានភាពពិតប្រាកដនោះទេ។ បណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម អំពីសេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ *មិនមានអ្វី* ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃ "បទចោទប្រកាន់" និងទាក់ទងតែទៅនឹងបញ្ហាថាតើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានសិទ្ធិ

---

75 **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥, កថាខណ្ឌ ១៩។

76 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣៨។

77 *សូមមើលផងដែរ*, សំណុំរឿង០០៣-**D174/1/4** [កោសលុប] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ ឲ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវ, ២៧ មេសា ២០១៦, យោបល់របស់ចៅក្រម Beauvallet និង Baik ទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះ, កថាខណ្ឌ ១៤-១៧។

78 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣៨។

អំណាចចោទប្រកាន់គាត់ *ដោយកំបាំងមុខ* ឬយ៉ាងណាតែប៉ុណ្ណោះ[79] (ដីកាសម្រេចដែលបានកើតចេញពីការបដិសេធរបស់ អ៊ឹម ចែម មិនសហការជាមួយតុលាការនេះ[80])។

៣២. មិនមានត្រង់ណានៅក្នុងការស៊ើបអង្កេត ដែល សចស និយាយថា មានភ័ស្តុតាងមិនគ្រប់គ្រាន់ទាក់ទងនឹងការចោទប្រកាន់ផ្នែកអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដែលមិនមាននៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់នោះឡើយ។ គ្មានការពន្យល់ ឬសំអាងហេតុណាមួយនៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ចំពោះមូលហេតុដែលថា ការចោទប្រកាន់ផ្នែកអង្គហេតុនានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនត្រូវបានដាក់បញ្ចូល[81]។ ដីកាដំណោះស្រាយ (សំអាងហេតុ) អនុវត្តតាមនេះដោយមិនបានពិចារណាឱ្យបានត្រឹមត្រូវ អំពីការចោទប្រកាន់ទាំងនោះលើមូលដ្ឋានដែលពួកវាមិនត្រូវបាន "ចោទប្រកាន់" ជាផ្លូវការនោះទេ[82]។ ផ្ទុយទៅនឹងការអះអាងរបស់ អ៊ឹម ចែម ការណ៍នេះមានតម្លៃស្មើទៅនឹងការកាត់បន្ថយ*តាមព្រឹត្តិន័យ*ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរដោយ សចស ដោយសារវាដកចេញនូវអង្គហេតុនានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា មុនពេលការចេញដីកាដំណោះស្រាយ[83]។ ដូចដែលសហព្រះរាជអាជ្ញាបានអះអាង[84] វិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលធ្វើនិយតកម្មការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដាក់កម្រិតដាច់ខាតថា ភាគីទាំងឡាយត្រូវបានជូនដំណឹងអំពីអង្គហេតុពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលត្រូវដកចេញ និងផ្តល់ឱ្យភាគីទាំងឡាយនូវឱកាសធ្វើសេចក្តីសន្និដ្ឋានលើការកាត់បន្ថយនេះ ដោយទទួលស្គាល់អំពីភាពអយុត្តិធម៌ជាមូលដ្ឋាន

---

79 **D239/1/2** បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការការពិនិត្យដោយកំបាំងមុខ, ២ មេសា ២០១៥។

80 *សូមមើល, ឧទា.,* **A150** ដីកាកោះលោកស្រី អ៊ឹម ចែមដើម្បីបង្ហាញខ្លួនលើកដំបូង, ២៩ កក្កដា ២០១៤។ **A151/2** លិខិតឆ្លើយតបទៅនឹងដីកាកោះអញ្ជើញមេធាវី ដោយ ស.ច.ស.អ, ១ សីហា ២០១៤។ **A122/6.1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំឲ្យរការអនុវត្តដីកាកោះហៅអ្នកស្រីឲ្យមកបង្ហាញខ្លួនជាលើកដំបូង, ១៥ សីហា ២០១៤។ **C1** ដីកាបង្គាប់ឲ្យនាំខ្លួន, ១៤ សីហា ២០១៤។

81 **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥។

82 **D308/3/1/**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទទ្បីករណ៍ទី១, កថាខណ្ឌ ១១-២២។

83 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៣៩។

84 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១៧។

នៃការលើកលែងការចោទប្រកាន់ណាមួយដោយមិនបានផ្ដល់ឱ្យភាគីនានានូវឱកាសទទួលបានការស្ដាប់សវនាការ។

## III. ទឡ្ហីករណ៍ទី២៖ សចស មានកំហុសផ្នែកអង្គច្បាប់ ដោយខកខានមិនបានដោះស្រាយអង្គហេតុនានាដែលត្រូវបានប្ដឹងទៅ សចស

៣៣. អ៊ឹម ចែម អះអាងថា មិនមានលក្ខខណ្ឌតម្រូវឱ្យ សចស "ធ្វើការបញ្ជាក់ពីការកំណត់លើបញ្ហាទាក់ទងនឹងការចោទប្រកាន់នីមួយៗរបស់ សពអ" ឡើយ ដរាបណា "មិនមានការចង្អុលបង្ហាញឱ្យឃើញថា សចស មិនបានយកចិត្តទុកដាក់ទាល់តែសោះលើរាល់បំណែកនៃភ័ស្តុតាងជាក់លាក់ណាមួយ"[85]។ ដូចដែលបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាបានបញ្ជាក់ច្បាស់ហើយ - សចស មិនត្រឹមតែចោលបំណែកជាក់លាក់នៃភ័ស្តុតាងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចោលការចោទប្រកាន់ទាំងមូល ព្រមទាំងភ័ស្តុតាងគាំទ្រដែលជាប់ជាមួយនឹងការចោទប្រកាន់ទាំងនោះដែរ[86]។

៣៤. ទោះបីជាការអះអាងរបស់ អ៊ឹម ចែម ថា "បញ្ហាសំខាន់នៅក្នុងសំណុំរឿង ០០៤ គឺយុត្តាធិការបុគ្គល"[87]ក៏ដោយ ក៏គាត់គេចវេះពីរបៀបដែលការវាយតម្លៃពីយុត្តាធិការបុគ្គលត្រូវបានធ្វើឡើងយ៉ាងពិតប្រាកដនោះ។ "សំអាងហេតុដ៏សាមញ្ញ"[88] របស់ អ៊ឹម ចែម ចំពោះអ្វីដែលត្រូវបានតម្រូវនៅពេលវាយតម្លៃ និងពិចារណាលើអង្គហេតុនានា មានតម្លៃស្មើទៅនឹងគ្មានលក្ខខណ្ឌតម្រូវសម្រាប់សំអាងហេតុណាមួយ កុំថាឡើយការរៀបរាប់អំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ។ វិធីសាស្ត្រខុសរបស់ អ៊ឹម ចែម ចំពោះភ័ស្តុតាងដែលពាក់ព័ន្ធទៅនឹងការកំណត់លើយុត្តាធិការបុគ្គល គឺត្រូវបានសង្ខេបនៅក្នុងការអះអាងជាដដែលៗរបស់គាត់ថា "មានកម្មាភិបាលជាងមួយរយនាក់ផ្សេងទៀតដែលមានឋានៈស្មើគ្នានាពេលនោះ"[89]។ ការលើកឡើងនេះគួរតែត្រូវដកចេញដោយសារមូលហេតុមួយចំនួន។ ទីមួយ អ៊ឹម ចែម បានបំភ្លៃការដកស្រង់នេះ ដោយបានមើលរំលងថា វាពាក់ព័ន្ធតែទៅនឹងចំនួនលេខាស្រុកដែលមានក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[90]។ ទីពីរ ការចាត់ថ្នាក់ដែលធ្វើឱ្យយល់ច្រឡំនេះ មិនរាប់បញ្ចូល៖ (i) តួនាទី និងសិទ្ធិ

---

85 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៤២។

86 **D308/3/1/1** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី២, កថាខណ្ឌ ២៣-៣៧។

87 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៤៣។

88 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៤៦។ *យោង*កថាខណ្ឌ ៤២-៤៤។

89 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៥, ៨៩។

90 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ៣១៦។

អំណាចរបស់ អ៊ឹម ចែម ក្នុងតំបន់១៣ នៃភូមិភាគនិរតី[91] (ii) តួនាទីរបស់ អ៊ឹម ចែម ក្នុងការដឹកនាំ និងចូលរួមក្នុងការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ ដោយកម្មាភិបាលភូមិភាគនិរតី[92] (iii) មុខតំណែងរបស់ អ៊ឹម ចែម ជាសមាជិកគណៈកម្មាធិការតំបន់ ៥[93] និង (iv) ការឡើងឋានៈជាបន្តបន្ទាប់របស់ អ៊ឹម ចែម មកជាអនុលេខាតំបន់ ៥[94]។

*(i) អ៊ឹម ចែម កំណត់លក្ខណៈខុសចំពោះភស្តុតាងទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ*

៣៥. អ៊ឹម ចែម កត់សម្គាល់ថា "សចស មានឆន្ទានុសិទ្ធិដាច់ខាតក្នុងការផ្តល់តម្លៃឲ្យភស្តុតាងនូវកម្រិតនៃភាពជឿជាក់តិចតួច ឬភស្តុតាងដែលគ្មានតម្លៃគួរជឿជាក់បានទាល់តែសោះក្នុងការទម្លាក់កំហុសកលើអ្នកស្រី អ៊ឹម ចែម ក្នុងបទចោទប្រកាន់លើពីអាពាហ៍ពិពាហ៍ដោយបង្ខំ"[95]។ ទោះជាយ៉ាងណា សចស មិនបានរកឃើញបែបនោះទេចំពោះតម្លៃភរនីយភាពនៃភស្តុតាងអំពីតួនាទីរបស់ អ៊ឹម ចែម ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។ អ៊ឹម ចែម បានបង្កើតការរកឃើញបែបនេះដើម្បីគេចវេះពីចំណុចមួយនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា- វាគឺជាការបរាជ័យរបស់ សចស ដែលមិនបាន*ពិចារណា*លើភស្តុតាងដែលត្រូវបានប្តឹងយ៉ាងត្រឹមត្រូវទៅពួកគាត់ ដែលជាចំណុចបញ្ហានៅក្នុងទឡ្ហីករណ៍នេះ។

៣៦. អ៊ឹម ចែម ព្យាយាមបន្ថយភស្តុតាងទាក់ទងនឹងការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅស្ពានស្រែង ថាគ្រាន់តែជាភស្តុតាងរបស់ "អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់"ប៉ុណ្ណោះ[96]។ ភស្តុតាងក្នុងបញ្ហានេះ គឺជាសក្ខីកម្មសវនាការរបស់ សែន សុផុន ក្នុងសំណុំរឿង០០២/២ និងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ក្នុងសំណុំរឿង ០០៤/១ ទាក់ទងនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ[97]។ ភស្តុតាងរបស់ សែន សុផុន មានភាពច្បាស់លាស់។ គាត់គឺជាកម្មករកងចល័តនៅស្ពានស្រែង និងបានឃើញការរៀប

---

91 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៤៣-១៥០។

92 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥២, ១៥៥-១៥៨, ១៦០, ១៧៣-១៧៦, ១៧៨-១៧៩, ១៨១-១៨៥ និង ៣០៨-៣១១។

93 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៦៦។

94 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៦៣។

95 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៦១។

96 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៥៨។

97 *សូមមើល*, **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២៧។

ពិធីអាអាពាហ៍ពិពាហ៍ដោយបង្ខំ[98]។ ពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ "កើតឡើងនៅក្រោមការគ្រប់គ្រងរបស់យាយចែម"[99]។

៣៧. ដូចគ្នានេះដែរ អ៊ឹម ចែម រិះគន់ភស្តុតាងស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ជនរងគ្រោះ ថង ធឿយ ដោយលើកឡើងថា "គ្មានសាលាក្តីមានហេតុផលណាមួយ អាចពឹងផ្អែកលើលក្ខណៈនៃភស្តុតាងដែលស្នើឡើងដោយ សពអ នោះទេ"[100]។ "លក្ខណៈនៃភស្តុតាងដែលស្នើឡើង" ដោយសហព្រះរាជអាជ្ញានេះ គឺគ្រាន់តែចង់ឲ្យពិចារណាលើភស្តុតាងរបស់បុគ្គលម្នាក់ ដែលត្រូវបានបង្ខំឲ្យរៀបការ ដោយការគំរាមកំហែងអំពីការសម្លាប់ នៅក្នុងពិធីមួយដែលគ្រប់គ្រងដោយ អ៊ឹម ចែម[101]ប៉ុណ្ណោះ។ ពិធីនេះត្រូវបានអនុវត្តតាមដោយបញ្ជារបស់ អ៊ឹម ចែម ទៅកាន់ថ្នាក់ក្រោមរបស់គាត់ដើម្បីឲ្យប្រាកដថា អាពាហ៍ពិពាហ៍នេះមានការរួមសង្វាស និងត្រូវសម្លាប់អ្នកដែលបដិសេធមិនព្រមរួមភេទចោល[102]។ ដីកាដំណោះស្រាយ (សំអាងហេតុ) មិនមានការយោងសំអាងណាមួយទៅលើភស្តុតាងដាក់បន្ទុកដ៏ខ្លាំងនេះទាក់ទងនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនេះឡើយ ហើយការបកស្រាយដ៏សមហេតុផលតែមួយគត់នៃការមិនបានធ្វើនេះគឺថា សចស មិនបានពិចារណាវានៅពេលធ្វើដីកាសម្រេចស្តីពីយុត្តាធិការបុគ្គលរបស់ខ្លួន។

៣៨. អ៊ឹម ចែម អះអាងថា "តក្កវិទ្យាដ៏សមទំនង" និង ថ្លែងថា "តាមនិយមន័យ" ភស្តុតាងនេះមិន "ផ្តល់ភស្តុតាងបានមធ្យ័តគ្រប់គ្រាន់ ស៊ីសង្វាក់ ឬដែលត្រូវបានបញ្ជាក់បន្ថែម [...] ដើម្បីផ្តល់ឲ្យបានច្រើនជាងភស្តុតាងគាំទ្រ" ចំពោះការចោទប្រកាន់ប្រឆាំងរូបគាត់នោះទេ[103]។ ប៉ុន្តែ ភស្តុតាងរបស់ ថង ធឿយ គឺមានភាពស៊ីសង្វាក់គ្នាទាំងស្រុង និង "មធ្យ័ត" ខ្លាំងណាស់។ ការចោទប្រកាន់របស់

98 *សូមមើល*, **D219/494.1.1** ប្រតិចារឹក សែន សុផុន, ២៧ កក្កដា ២០១៥, 15.49.35-15.51.40។

99 **D219/506** កំណត់ហេតុនៃការស្តាប់ចម្លើយ សែន សុផុន, ១៥ កញ្ញា ២០១៥, ឆ.៥១-៥៣។

100 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៦០។

101 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២៧, *យោង* D304/2 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម, ២៧ តុលា ២០១៦, កថាខណ្ឌ ១៣២។

102 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ២៧, *យោង* D304/2 ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម, ២៧ តុលា ២០១៦, កថាខណ្ឌ ១៣២។

103 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៦០។

អ៊ឹម ចែម ដែលថា សក្ខីកម្មរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មបែបនេះត្រូវតែបញ្ជាក់បន្ថែមដោយសាក្សីផ្សេងទៀតដើម្បីមានតម្លៃអាចជឿជាក់បាននោះ គឺផ្ទុយទៅនឹងយុត្តិសាស្ត្រអន្តរជាតិ ដែលនៅក្នុងនោះ សូម្បីតែការផ្តន្ទាទោសនៅសវនាការក៏អាចផ្អែកលើភស្តុតាងពីសាក្សីតែម្នាក់ដែរ[104]។ ភស្តុតាងរបស់សាក្សីផ្ទាល់ភ្នែកដែលបានស្បថ និងជនរងគ្រោះ គឺពិតជាលើសពីលទ្ធភាពដែលអាចបំពេញតាមបទដ្ឋាននៃ "ភវនីយភាព" ដែលអាចអនុវត្តបានចំពោះដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីផ្តន្ទាទោសទៅទៀត។

*(ii) អ៊ឹម ចែម កំណត់លក្ខណៈខុសចំពោះភស្តុតាងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាម*

៣៩. អ៊ឹម ចែម កំណត់លក្ខណៈខុសចំពោះការរកឃើញរបស់ សចស ទាក់ទងនឹងវត្តព្រះនេត្រព្រះ[105]។ ការអះអាងរបស់ អ៊ឹម ចែម ដែលថា សចស បានរកឃើញថា "ព្រំដែនច្បាស់លាស់នៃសិទ្ធិអំណាច [របស់ អ៊ឹម ចែម] ទៅលើបញ្ហានានាពាក់ព័ន្ធនឹងថ្នាក់តំបន់" មិនត្រូវបានកំណត់និយមន័យ មានន័យថា សិទ្ធិអំណាចរបស់គាត់លើវត្តព្រះនេត្រព្រះមានភាពមិនច្បាស់លាស់នោះ គឺមិនត្រឹមត្រូវនោះទេ[106]។ វត្តព្រះនេត្រព្រះស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ហើយ សចស បានរកឃើញយ៉ាងច្បាស់លាស់ទាក់ទងនឹងសិទ្ធិសំណាចរបស់ អ៊ឹម ចែម ក្នុងឋានៈជាលេខាស្រុកនេះ[107]។ ការខ្វះចន្លោះរបស់ សចស ក្នុងការសន្និដ្ឋានលើតួនាទីរបស់ អ៊ឹម ចែម ក្នុងគណៈកម្មាធិការតំបន់៥ មិនបានធ្វើឱ្យប្រែប្រួលដល់ការវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះវត្តព្រះនេត្រព្រះនោះឡើយ[108]។

៤០. ការអះអាងរបស់ អ៊ឹម ចែម ទាក់ទងនឹងភស្តុតាងរបស់ ម៉ក់ វន្នី ក៏មិនត្រឹមត្រូវផងដែរ។ សចស មិនបានរកឃើញថាចម្លើយរបស់ ម៉ក់ វន្នី អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាមនៅទីតាំង

---

104 *សូមមើល, ឧទា., រដ្ឋអាជ្ញា ទល់នឹង* *Duško Tadić*, IT-94-1-A, ICTY, សាលដីកា, ១៥ កក្កដា ១៩៩៩, កថាខណ្ឌ ៥៧, ៦៥-៦៦។ *រដ្ឋអាជ្ញា ទល់នឹង Zlatko Aleksovski, IT-95-14/1-A,* ICTY, សាលដីកា, ២៤ មីនា ២០០០, កថាខណ្ឌ ៥៧, ៦២, ៦៣។ *រដ្ឋអាជ្ញា ទល់នឹង Dario Kordić and Mario Čerkez,* IT-95-14/2-A, ICTY, សាលដីកា, ១៧ ធ្នូ ២០០៤, កថាខណ្ឌ ២៧៤-២៧៥, ២៩៣។

105 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៦៣-៦៤។

106 *ផ្ទុយទៅនឹង,* **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៦៣-៦៤។

107 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៦៧-១៨៨។

108 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥៨-១៦០, ១៦៦, ១៧៣-១៧៥, ១៧៧-១៧៩, ១៨០-១៨៨, ២៥៩។

សម្លាប់មនុស្សព្រៃតារុត "មិនអាចទុកចិត្តបាន និងមានតម្លៃជាភស្តុតាងតិចតួច" នោះឡើយ[109]។ សចស ធ្វើការសន្និដ្ឋាននោះពាក់ព័ន្ធទៅនឹងរបាយការណ៍ដែលរៀបចំឡើងដោយ DC-Cam និងស្ថាប័នផ្សេងទៀត[110] មិនមែនកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ម៉ក់ វន្នី នោះទេ។

*(iii) អ៊ឹម ចែម កំណត់លក្ខណៈខុសចំពោះភស្តុតាងពាក់ព័ន្ធនឹងការបោសសម្អាតភូមិភាគពាយ័ព្យ*

៤១. ការអះអាងរបស់ អ៊ឹម ចែម ថា ដីកាដំណោះស្រាយ (សំអាងហេតុ) គ្រាន់តែបានរកឃើញថា "បានដឹកនាំការផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ"[111] និង "បានច្រានចោលការអះអាងថាគាត់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ" ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការបោសសម្អាតភូមិភាគពាយ័ព្យនោះ[112] គឺផ្ទុយគ្នាតាមរយៈការអានដីកាដំណោះស្រាយនេះ។ សចស បានរកឃើញ *ជាអាទិ៍៖*

> "លើកទីពីរធ្វើឡើងនៅឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨ នៅពេល តាម៉ុក បញ្ជូនកម្មាភិបាលភូមិភាគនិរតី រួមជាមួយក្រុមគ្រួសារពួកគេ ដើម្បីទៅចាប់ខ្លួន និងជំនួសកម្មាភិបាលភូមិភាគពាយ័ព្យនៅថ្នាក់ឃុំ សហករណ៍ និងស្រុក ដែលដឹកនាំដោយ អ៊ឹម ចែម"[113]។

> "តាម៉ុក បានបញ្ជូន ៥០០ ទៅ ៦០០ គ្រួសារ តាមរថភ្លើងពីតាកែវ ក្នុងភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ។ អ៊ឹម ចែម ជាអ្នកដឹកនាំក្រុមក្នុងការបញ្ជូននាពេលនោះ ។ ក្រុមនេះមានទាហានចំនួនពី ៣០០ ទៅ ៥០០ នាក់ដែរ បានឈប់សម្រាកមួយឬពីរយប់នៅភ្នំពេញ មុននឹងទៅដល់ភូមិភាគពាយ័ព្យ។ នៅភ្នំពេញ ប៉ុល ពត បានដឹកនាំអង្គប្រជុំដល់ពួកគេ ចំណែក អ៊ឹម ចែម អង្គុយនៅកៅអីជួរមុខ"[114]។

---

109 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៦៧។

110 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៣៥។

111 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៥៥។

112 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៥៦។

113 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥២។

114 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥៦។

"បន្ទាប់ពីកម្មាភិបាលនិរតី និង អ៊ឹម ចែម ចូលគ្រប់គ្រងតំបន់ ៥ នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ មក ពួកគេបានអនុវត្តយុទ្ធនាការធ្វើការចាប់ខ្លួនជាប្រព័ន្ធដែលដាក់មុខសញ្ញាលើកម្មាភិបាលពាយ័ព្យ នៅថ្នាក់សហករណ៍ ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់"[115]។

"ក្រោយពេលកម្មាភិបាលភូមិភាគនិរតីទៅដល់ កងទ័ព និងកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅតាមមន្ទីរសន្តិសុខនានាក្នុងភូមិភាគពាយ័ព្យ និងនៅមន្ទីរ ស-២១ នៅភ្នំពេញ ដោយចាត់តាំងឲ្យធ្វើការងារនៅតាមការដ្ឋាននានាក្នុងភូមិភាគពាយ័ព្យដើម្បី "កសាងខ្លួន" ឬយកទៅសម្លាប់"[116]។

"តាម៉ុក បានបោសសម្អាតតំបន់ ៥ នៃភូមិភាគពាយ័ព្យ ដែលនៅទីនោះ មេដឹកនាំមូលដ្ឋាន និងកម្មាភិបាលថ្នាក់ក្រោម ត្រូវបានចាប់ខ្លួន និងសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី ចាប់ពីពាក់កណ្ដាលឆ្នាំ ១៩៧៧ មក។ [...] អ៊ឹម ចែម បានផ្លាស់ទៅតំបន់ ៥ នៃភូមិភាគពាយ័ព្យនៅពាក់កណ្ដាលឆ្នាំ ១៩៧៧ និងជំនួសអតីតកម្មាភិបាលពាយ័ព្យ ទាំងនៅថ្នាក់ស្រុក និងតំបន់"[117]។

"តាម៉ុក អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតីដទៃទៀត មានផែនការរួមគ្នាក្នុងការផ្លាស់ប្ដូរកម្មាភិបាលពាយ័ព្យនៅក្នុងរដ្ឋបាលនៃភូមិភាគពាយ័ព្យ និងក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ឲ្យបានជោគជ័យ។ ពួកគេអនុវត្តការងារទាំងនេះតាមរយៈការចាប់ខ្លួន និងសម្លាប់កម្មាភិបាលនៅទីកន្លែងនៅគ្រប់កម្រិតទាំងអស់នៃរដ្ឋបាល ចាប់តាំងពីកម្រិតភូមិភាគ រហូតដល់កម្រិតសហករណ៍"[118]។

៤២. ទាក់ទងនឹងការពិចារណាអំពីលទ្ធផលនៃឧក្រិដ្ឋកម្ម អ៊ឹម ចែម បានការពារការបរាជ័យរបស់សចស ក្នុងការផ្ដល់ទម្ងន់ដល់តួនាទីរបស់គាត់ ក្នុងការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ ដោយបានអះអាងថា "*ព័ត៌មានពិស្ដារ*នៃឧក្រិដ្ឋកម្ម (ផ្ទុយទៅនឹងចរិតលក្ខណៈសំខាន់ៗនៃឧក្រិដ្ឋកម្មទាំងនោះ និងចំណងទំនាក់ទំនងទៅនឹងអ្នកស្រី អ៊ឹម ចែម) គឺពាក់ព័ន្ធតិចតួចណាស់

115 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៨៥។

116 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥៣។

117 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៥៤។

118 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ៣០៨។

ក្នុងការកំណត់យុត្តាធិការបុគ្គល"[119]។ អ៊ឹម ចែម មិនបានពន្យល់អំពីមូលហេតុដែលគាត់ចាត់ទុកថា ការខកខាន របស់ សចស មិនបានពិចារណាអំពីការសម្លាប់ប្រជាជនយ៉ាងតិចបំផុតចំនួន ១២០០ នាក់[120] គឺគ្រាន់តែជា "ព័ត៌មានពិស្តារ" និង "ពាក់ព័ន្ធតិចតួចណាស់" ទៅនឹងការវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម។ ការចូលរួមចំណែករបស់ជនត្រូវចោទក្នុងឧក្រិដ្ឋកម្ម ដែលមានស្ថានទម្ងន់បែបនេះ គឺច្បាស់ណាស់ជាជំហានចាំបាច់មួយក្នុងការពិចារណាណាមួយអំពីថាតើជនសង្ស័យស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" និងស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា។

*(iv) អ៊ឹម ចែម បកស្រាយខុសអំពីភ័ស្តុតាងពាក់ព័ន្ធទៅនឹងការចោទប្រកាន់ជាច្រើនផ្សេងទៀត*

៤៣. អ៊ឹម ចែម មិនជំទាស់ទៅនឹងការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា ដីកាដំណោះស្រាយខកខានមិនបានពិចារណាលើអង្គហេតុនានា ដែល សចស ត្រូវបានប្តឹងនោះឡើយ ទាក់ទងនឹងការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខភ្នំត្រយោង និងមន្ទីរសន្តិសុខចំការខ្នុរ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការបាត់ខ្លួនដោយបង្ខំនៅវត្តអង្គសិរីមាលី និងលក្ខខណ្ឌរស់នៅអមនុស្សធម៌នៅមន្ទីរសន្តិសុខចំការខ្នុរ[121]។ សេចក្តីសន្និដ្ឋានតែមួយគត់របស់ អ៊ឹម ចែម លើចំណុចនេះគឺថា បណ្តឹងឧទ្ធរណ៍នេះមិនផ្តល់ "ការពន្យល់វែកញែកថាតើកំហុសណាមួយ ដែលញាំងឲ្យមានការធ្វើមោឃភាពលើការរកឃើញនានានៃដីកាដំណោះស្រាយ ឬបើមិនដូច្នោះទេ ក៏ត្រូវបង្ហាញហេតុផលដែលបង្កឲ្យមានជាការបំពានឆន្ទានុសិទ្ធិ"[122]។ ច្បាស់លាស់ណាស់ ព័ត៌មានពិស្តារអំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើង គឺពាក់ព័ន្ធជារួមទៅនឹងការសម្រេចអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ និងចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងនោះ។ ការខកខានរបស់ សចស មិនបានវាយតម្លៃលើភ័ស្តុតាងស្តីពីអង្គហេតុ ដែលត្រូវបានប្តឹងទៅកាន់ខ្លួន និងមិនបានធ្វើការសម្រេចត្រឹមត្រូវអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម សម្រាប់គោលបំណងនៃការកំណត់អំពីយុត្តាធិការបុគ្គលនេះ ស្ថិតនៅក្នុងចំណុចស្នូលនៃបណ្តឹងឧទ្ធរណ៍នេះ។

[119] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៥៦ (គូសបញ្ជាក់ក្នុងច្បាប់ដើម)

[120] **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៦។

[121] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៧២។

[122] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៧២។

## IV. ទឡ្ហីករណ៍ទី៣÷ សចស មានកំហុសអង្គច្បាប់ និងអង្គហេតុ នៅពេលកំណត់និយមន័យឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការអនុវត្តនិយមន័យនេះទៅលើការរកឃើញផ្សេងៗទៀត

៤៤. ផ្ទុយទៅនឹងការស្នើឡើងខុសរបស់ អ៊ឹម ចែម ដែលថា សហព្រះរាជអាជ្ញាកំពុងតែជំទាស់ទៅនឹង "បញ្ហាជាក់លាក់មួយចំនួននៃបទល្មើសសំខាន់ៗ"[123] សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការអនុវត្តមិនត្រឹមត្រូវនៃច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល[124]។ ពិតដូចគ្នាទៅនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងទឡ្ហីករណ៍ទី៤[125]។ ការបំភាន់របស់ អ៊ឹម ចែម អំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញានេះ គឺជាការប៉ុនប៉ងចាត់ថ្នាក់ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាឲ្យហួសពីវិសាលភាពនៃការពិនិត្យបណ្តឹងឧទ្ធរណ៍។ ទោះជាយ៉ាងណា ការអានស៊ើបៗនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាបង្ហាញឲ្យឃើញអំពីកំហុសនៃអំណះអំណាងរបស់ អ៊ឹម ចែម[126]។ សចស បានមិនបានអនុវត្តច្បាប់ដែលមានការឯកភាព និងដែលបានកំណត់យ៉ាងត្រឹមត្រូវនោះ ដោយសារវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ ក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងទៀត[127]។ អំណះអំណាងរបស់សហព្រះរាជអាជ្ញាមិនមែនមួយក្នុងចំណោមនិយមន័យទាំងឡាយនោះទេ ប៉ុន្តែក្នុងចំណោមការអនុវត្តមិនត្រឹមត្រូវនៃច្បាប់ដែលមាន[128]។ អ៊ឹម ចែម គាំទ្រគោលជំហរដែលនឹងរារាំងយ៉ាងមានប្រសិទ្ធិភាពដល់ការកែប្រែកំហុសផ្នែកច្បាប់ដ៏ច្បាស់ក្រឡែត និងមិនបានផ្តល់ជម្រើសសម្រាប់បណ្តឹងឧទ្ធរណ៍ទេ។ ការណ៍នេះវាផ្ទុយទៅនឹងគោលការណ៍គតិយុត្តជាមូលដ្ឋាន។ ជាងនេះទៀត អ៊ឹម ចែម មើលរំលងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដែលនៅក្នុងនោះអង្គបុរេជំនុំជម្រះបានពិនិត្យយ៉ាងច្បាស់លាស់នូវនិយមន័យនៃឧក្រិដ្ឋកម្មក្នុងប្រទេសកម្ពុជា និងអន្តរជាតិ ដោយរួមបញ្ចូលទាំងការពិនិត្យយ៉ាងជាក់លាក់លើ *ចេតនាឧក្រិដ្ឋ*នៅក្នុងនោះ នៅលើបណ្តឹងឧទ្ធរណ៍[129]។

---

123 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ២២។

124 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៣, កថាខណ្ឌ ៣៨-៤៦។

125 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៤, កថាខណ្ឌ ៤៧-៥៧។

126 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៨-៥៧។

127 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៨-៥៧។

128 *ផ្ទុយទៅនឹង*, **D308/3/1/1** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ២៣។

129 **D99/3/42** សាលដីកា របស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ ៥៩-៨១។

៤៥. អ៊ឹម ចែម អះអាងថា ពីព្រោះ សចស បានសន្និដ្ឋានថា តុលាការនេះមិនមានយុត្តាធិការបុគ្គល "សំណួរចោទស្តីពីបញ្ហានៃការមាន*ចេតនាឧក្រិដ្ឋ*របស់អ្នកស្រី អ៊ឹម ចែម ដែលជាបញ្ហាមួយមិនត្រូវបានរកឃើញសម្រាប់ធ្វើការពិចារណា ហើយក៏មិនត្រូវបានធ្វើការវាយតម្លៃលើបញ្ហានេះដែរ"[130]។ ការបកស្រាយច្បាប់ដ៏ចម្លែកនេះ បង្ហាញថា ភ័ស្តុតាងដែលការសម្រេចអំពីយុត្តាធិការបុគ្គល ត្រូវបានធ្វើឡើងនោះ មិនត្រូវបានវាយតម្លៃនោះទេ - ហើយតាមទស្សនៈរបស់ អ៊ឹម ចែម មិនចាំបាច់វាយតម្លៃនោះឡើយ[131]។

៤៦. អំណះអំណាងរបស់ អ៊ឹម ចែម ទាក់ទងនឹងបទដ្ឋាន*ចេតនាឧក្រិដ្ឋ*ដែលត្រូវបានអនុវត្តចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលនៅក្នុងដីកាដំណោះស្រាយ គឺមានលក្ខណៈមិនស៊ើសង្វាក់គ្នាយ៉ាងខ្លាំង។ អ៊ឹម ចែម អះអាងថា "សចស មិនបានបញ្ចូលលក្ខខណ្ឌតម្រូវឲ្យមានការព្យាករ *ជាមុន* ទៅក្នុងធាតុផ្សំរបស់ *ចេតនាឧក្រិដ្ឋ* នៃបទឧក្រិដ្ឋកម្ម [សម្លាប់រង្គាល] នោះទេ"[132] និងថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា សចស បានធ្វើដូច្នោះគឺមិនមានការគាំទ្រដោយ "ទាំងការអានត្រង់ៗ ឬក៏អានក្នុងបំណងជាក់លាក់នៃដីកាដំណោះស្រាយ"[133]។ ទោះជាយ៉ាងណា ក្នុងពេលជាមួយគ្នានេះដែរ អ៊ឹម ចែម ថ្លែងថា "ការសន្និដ្ឋានរបស់ សចស ដែលតម្រូវថា ភ័ស្តុតាងគប្បីបង្កើតឲ្យឃើញនូវការប៉ុនប៉ង *ជាមុន* ក្នុងកាលៈទេសៈជាក់ស្តែងនៃទិដ្ឋភាពសំណុំរឿងក្តីនេះ សបញ្ជាក់ឲ្យឃើញថា គ្មានបំណងនឹងធ្វើការណែនាំឲ្យប្រើនូវ ធាតុផ្សំច្បាប់ថ្មី"[134]។

៤៧. អ៊ឹម ចែម កំណត់លក្ខណៈលក្ខខណ្ឌតម្រូវថ្មីប្លែកនៃ*ចេតនាឧក្រិដ្ឋជាមុន* ថាគ្រាន់តែជា "ភ័ស្តុតាងតម្រូវដ៏សមហេតុផលមួយ"[135] សម្រាប់បង្កើត*ចេតនាឧក្រិដ្ឋ*ដែលចាំបាច់ទាក់ទងនឹងការសម្លាប់ដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំត្រយោង។ ការអះអាងរបស់ អ៊ឹម ចែម ខុសទាំងខាងអង្គហេតុ និងអង្គច្បាប់។ ទីមួយ ផ្ទុយទៅនឹង ការរៀបរាប់របស់ អ៊ឹម ចែម អំពីការសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោង "ថាមានលក្ខណៈដាច់ដោយឡែកពីគ្នា" និងត្រូវបានធ្វើឡើងដោយចារី "ខុស

---

130 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៧៥។

131 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៧៥។

132 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៧៩។

133 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៧៨-៧៩។

134 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨០។

135 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨២។

ស្រឡះពីគ្នា"[136] សចស បានប៉ាន់ប្រមាណថា "អ្នកទោសជាង ២០០០ នាក់ ត្រូវអ្នកយាមគុកសម្លាប់នៅចន្លោះពេលពីកណ្ដាលឆ្នាំ ១៩៧៧ ដល់ខែ មករា ឆ្នាំ ១៩៧៩"[137] និង "មានមនុស្សរាប់រយនាក់បានស្លាប់ដោយសារអត់អាហារ"[138]។ ទាំងនេះមិនមែនជាហេតុការណ៍ដែលព្រាវៗ ឬមិនមានទំនាក់ទំនងគ្នានោះឡើយ[139]។ អ្នកជាប់ឃុំ "ជាប្រចាំត្រូវបានសម្លាប់"[140] ហើយ"អ្នកយាមបានអួតអំពីការសម្លាប់អ្នកទោស ហើយអួតគ្នាថានរណាសម្លាប់បានច្រើនជាង"[141]។ ជាងនេះទៀត ការជាប់ពាក់ព័ន្ធ និងចេតនារបស់ អ៊ឹម ចែម ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយអង្គហេតុនានាដែលត្រូវបានរកឃើញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)។ អ៊ឹម ចែម មាន "សិទ្ធិអំណាចជាទូទៅ" លើមន្ទីរសន្តិសុខភ្នំត្រយោង និង "បានគ្រប់គ្រងប្រតិបត្តិការមន្ទីរនេះ"[142]។ អ៊ឹម ចែម បានតែងតាំង ទុំ សឿន ឲ្យទទួលបន្ទុកភ្នំត្រយោង[143]។ អ៊ឹម ចែម គឺជា "មេផ្ទាល់" របស់គាត់ - ទុំ សឿន "រាយការផ្ទាល់ទៅគាត់" ហើយគាត់ "ទទួលបញ្ជាពី អ៊ឹម ចែម បើមិនដោយផ្ទាល់ ក៏តាមរយៈនិរសាររបស់គាត់ដែរ"[144]។ អ៊ឹម ចែម "បានរៀបចំអង្គប្រជុំប្រចាំខែ ឬកន្លះខែម្ដង ជាមួយនឹងប្រធានសហករណ៍ និង ទុំ សឿន ដើម្បីសម្រេចថា តើនរណាត្រូវបញ្ជូនទៅមន្ទីរសន្តិសុខនេះ"[145]។ អ្នកទោសត្រូវបានចាប់ខ្លួន "ដោយផ្អែកតាមលិខិតចុះហត្ថលេខាដោយ អ៊ឹម ចែម ឬដោយកម្មាភិបាលផ្សេងទៀតថ្នាក់តំបន់ ហើយបញ្ជូនមកគាត់តាមរយៈ អ៊ឹម ចែម"[146]។ ទុំ សឿន បានសារភាពពីការសម្លាប់អ្នកទោស "តាមបញ្ជារបស់ អ៊ឹម ចែម"[147]។

---

[136] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨១។

[137] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៨៩។

[138] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២២០។

[139] *ផ្ទុយទៅនឹង* **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨១-៨២។

[140] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២០៨។

[141] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២០៩។

[142] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៩៥។

[143] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៩២។

[144] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១៩៥។

[145] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២០០។

[146] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២០០។

[147] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២០១, ២១២។

៤៨. ទីពីរ អ៊ឹម ចែម អះអាងថា ឧក្រិដ្ឋកម្មសម្លាប់រង្គាលតម្រូវឲ្យមានធាតុផ្សំបន្ថែមដើម្បីបញ្ជាក់បាន *ដោយផ្អែកទៅលើកាលៈទេសៈនៃរឿងក្តីនេះ*[148]។ ការអះអាងរបស់ អ៊ឹម ចែម ដែលថា ការដកចេញនូវចេតនា*ជាមុន* មានហានិភ័យដល់ការរំលោភលើគោលការណ៍កំណត់លើបញ្ហាពិរុទ្ធភាព[149] ខកខានក្នុងការធ្វើយុត្តិកម្មការដាក់បញ្ចូលធាតុផ្សំថ្មីទៅក្នុងឧក្រិដ្ឋកម្មសម្លាប់រង្គាលនេះ។ ច្បាស់ណាស់ និងផ្ទុយទៅនឹងការស្នើឡើងរបស់ អ៊ឹម ចែម ការណ៍នេះមិន "ស្របតាមបទដ្ឋានវិធីសាស្ត្រអន្តរជាតិចំពោះឧក្រិដ្ឋកម្ម [សម្លាប់រង្គាល]"[150]។ លក្ខខណ្ឌតម្រូវច្រើនឥតគណនានៃការសម្លាប់រង្គាល អាចត្រូវបានបំពេញតាមរយៈការសម្លាប់ជាបន្តបន្ទាប់ ឬលំដាប់លំដោយនៃការប្រព្រឹត្ត[151] និងមិនមានមូលដ្ឋានគតិយុត្តណាតម្រូវថា ចារីបង្កើតចេតនាដើម្បីសម្លាប់ក្នុងចំនួន "ដ៏ច្រើន" នៅពេលចាប់ផ្តើមនៃការសម្លាប់ជាបន្តបន្ទាប់ ផ្ទុយទៅនឹងចំណុចណាមួយក្នុងអំឡុងពេលនៃការសម្លាប់ទាំងនោះ[152]។

## V. **ឧទ្ធរណ៍ទី៤៖ សចស មានកំហុសអង្គច្បាប់ និងអង្គហេតុ នៅពេលកំណត់និយមន័យឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ និងការអនុវត្តនិយមន័យនេះទៅលើការរកឃើញទាំងឡាយ**

៤៩. អ៊ឹម ចែម និយាយឡើងវិញនូវគោលជំហរច្បាប់មិនសមទំនងទាក់ទងនឹងការវាយតម្លៃភ័ស្តុតាងអំពីការទទួលខុសត្រូវ ដោយថ្លែងថា "ជាលទ្ធផល ដីកាសម្រេចរបស់ សចស ដែល អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គល គឺជាសំណួរចោទគឺនៅត្រង់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកស្រី អ៊ឹម ចែម ចំពោះការបាត់ខ្លួនដោយបង្ខំ មិនបានស្តែងឲ្យឃើញឡើងសម្រាប់ត្រូវធ្វើការពិចារណាវិញទេ"[153]។ ការពិនិត្យលើដីកាដំណោះស្រាយបង្ហាញឲ្យឃើញនូវតថភាពខុសពីនេះ។ សចស បានសម្រេចថា

---

148 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨០-៨៥។

149 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨៥។

150 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨២។

151 *សូមមើល ឧទា.*, **F36** សាលដីកាបណ្តឹងសាទុក្ខ សំណុំរឿង០០២/១, កថាខណ្ឌ ៥៥១-៥៥២។ *រដ្ឋអាជ្ញា ទល់នឹង* Stanišić & Župljanin IT-08-91-A សាលដីកាបណ្តឹងឧទ្ធរណ៍, ៣០ មិថុនា ២០១៦, កថាខណ្ឌ១០២២។ *រដ្ឋអាជ្ញា ទល់នឹង* *Zdravko Tolimir* IT-05-88/2-A សាលដីកាបណ្តឹងឧទ្ធរណ៍, ៨ មេសា ២០១៥, កថាខណ្ឌ ១៤៧។ *រដ្ឋអាជ្ញា ទល់នឹង Nyuramasuhuko និងគូកន.*, ICTR-98-42-A, សាលដីកាបណ្តឹងឧទ្ធរណ៍, ១៤ ធ្នូ ២០១៥, កថាខណ្ឌ ២១២៥-២១២៦។

152 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៨-៤៥។

153 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៩២ (គូសបញ្ជាក់ក្នុងច្បាប់ដើម)។

មិនមានភស្តុតាងដែលគ្រួសាររបស់អ្នកដែលបានបាត់ខ្លួន ស្វែងរកព័ត៌មានអំពីជោគវាសនា និងទីកន្លែងរបស់អ្នកដែលបានបាត់ខ្លួនទាំងនោះទេ និងថា "ដោយសារមូលហេតុនេះតែមួយ ភស្តុតាងមិនអាចអនុញ្ញាតឲ្យយើងសន្និដ្ឋានបានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំត្រូវបានប្រព្រឹត្តឡើង"[154]។

៥០. អ៊ឹម ចែម បានអះអាងមិនត្រឹមត្រូវថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា "ជាករណីស្នើសុំឲ្យមានការពិនិត្យមើលឡើងវិញនូវវិធីសាស្ត្ររបស់ សចស លើការកំណត់ខ្សែបន្ទាត់ជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការបាត់ខ្លួនដោយបង្ខំ ថាជាអំពើអមនុស្សធម៌ផ្សេងទៀតឡើយ ហេតុដូច្នេះ សំណើនេះវាស្ថិតនៅក្រៅវិសាលភាពនៃអំណាចរបស់ អបជ ក្នុងការពិនិត្យឡើងវិញ"[155]។ ការណ៍នេះកំណត់លក្ខណៈខុសចំពោះបណ្តឹងឧទ្ធរណ៍នេះ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានស្នើសុំថា អង្គបុរេជំនុំជម្រះកែតម្រូវកំហុសដ៏ច្បាស់លាស់មួយរបស់ សចស អំពីអនុវត្តនិយមន័យនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ក្នុងរូបភាពជាឧក្រិដ្ឋកម្មដាច់តែឯង ជាជាងការធ្វើឲ្យបាត់ខ្លួនដោយបង្ខំក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងទៀត ដែលជាលទ្ធផលនាំឲ្យមានការវាយតម្លៃខុសអំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ អ៊ឹម ចែម។ បណ្តឹងឧទ្ធរណ៍នេះស្នើសុំថា អង្គបុរេជំនុំជម្រះអនុវត្តច្បាប់ដែលត្រឹមត្រូវ ដូចដែលបានកំណត់ដោយសាលដីកាលើបណ្តឹងសាទុក្ខនៃអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២/១[156] និងធ្វើការវាយតម្លៃឡើងវិញ ឬបញ្ជូនសំណុំរឿងត្រឡប់ទៅ សចស វិញដើម្បីធ្វើការវាយតម្លៃឡើងវិញលើដីកាសម្រេចស្តីពីយុត្តាធិការបុគ្គលនេះ។

៥១. អ៊ឹម ចែម បានលើកឡើងថា "មានការគាំទ្រតិចតួចសម្រាប់សេចក្តីអះអាងរបស់ សពអ ដែលថា សចស បានអនុវត្តប្រាសចាកពីនិយមន័យនៃការបាត់ខ្លួនដោយបង្ខំថាជាអំពើអមនុស្សធម៌ផ្សេងទៀត"[157]។ ទោះជាយ៉ាងណា ការអានសាលដីកាលើបណ្តឹងសាទុក្ខនៃអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២/១ ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំក្នុងរូបភាពជាអំពើអមនុស្សធម៌ផ្សេងទៀត និងការប្រៀបធៀបវាទៅនឹងនិយមន័យនៃឧក្រិដ្ឋកម្មនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ដែលបានអនុវត្តទៅលើអង្គហេតុនៅក្នុងដីកាដំណោះស្រាយ បង្ហាញឲ្យឃើញនូវកំហុស

---

154 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ៣០២ (គូសបញ្ជាក់បន្ថែម)។

155 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៩២។

156 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៤, កថាខណ្ឌ ៤៧-៥៧។

157 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៩៤។

អង្គច្បាប់[158]។ អង្គជំនុំជម្រះតុលាការកំពូលបានរៀបរាប់អំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានអនុម័តដោយ សចស នៅក្នុងដីកាដំណោះស្រាយនេះ ថាជា "ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់ឡើយ"[159]។ បញ្ហាតែមួយ "ដែលមានការពាក់ព័ន្ធ" នោះគឺថាតើ "អំពើប្រព្រឹត្តដែលចោទជាបញ្ហា ដោយផ្អែកលើកាលៈទេសៈជាក់លាក់ទាំងអស់នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ជាក់ស្តែងបានបំពេញតាមការកំណត់និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែរឬយ៉ាងណា"[160]។ ប៉ុន្តែ សចស បានជ្រើសរើសអនុវត្តតាមអង្គជំនុំជម្រះសាលាដំបូង ដោយមិនបានអនុវត្តនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងទៀតទៅលើអង្គហេតុទាំងឡាយ ប៉ុន្តែបែជាអនុវត្តនិយមន័យនៃឧក្រិដ្ឋកម្មនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា មិនមែនជាឧក្រិដ្ឋកម្មដែលត្រូវបានទទួលស្គាល់តាមច្បាប់ទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥[161]។

៥២. អ៊ឹម ចែម បានអះអាងបន្ថែមថា វា "មិនអាចសន្មតបានថា" ការបាត់ខ្លួនបណ្តាលឱ្យមានជាការរងគ្រោះយ៉ាងធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្ត[162]។ វាមិនមានការសន្មតបែបដូច្នេះទុកជាមុននោះទេ ថាវាជាការចាំបាច់នោះ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/១ នៅពេលដែលបានលើកឡើងពីចំណុចចាប់ផ្តើមនៃអំពើអមនុស្សធម៌ បានសម្រេចថា ការជម្លៀសចេញពីទីក្រុងភ្នំពេញ៖

> បានរំលោភបំពានលើសិទ្ធិមានសេរីភាព សិទ្ធិមានសន្តិសុខរបស់បុគ្គល និងសេរីភាពក្នុងការដើរហើរ និងតាំងទីជម្រក។ នៅក្នុងកាលៈទេសៈពាក់ព័ន្ធទៅនឹងរូបកាយ ការជម្លៀសនេះបានរំលោភបំពានលើសេរីភាពតាមរយៈអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។ ដូច្នេះ ការជម្លៀសនេះ បានបង្កការរងទុក្ខផ្នែករូបកាយ និងផ្លូវចិត្ត និងព្យសនកម្មធ្ងន់ធ្ងរ និងជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[163]។

---

158 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៤, កថាខណ្ឌ ៤៧-៥៧។

159 សាលដីកាបណ្តឹងសាទុក្ខ សំណុំរឿង០០២/១- **F36**, ២៣ វិច្ឆិកា ២០១៦, កថាខណ្ឌ ៥៨៩ ("សាលដីកាបណ្តឹងសាទុក្ខ សំណុំរឿង០០២/១")។

160 **F36** សាលដីកាបណ្តឹងសាទុក្ខ សំណុំរឿង០០២/១, កថាខណ្ឌ ៥៨៩។

161 **F36** សាលដីកាបណ្តឹងសាទុក្ខ សំណុំរឿង០០២/១, កថាខណ្ឌ ៥៨៩។

162 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៩៨។

163 **F36** សាលដីកាលើសំណុំរឿង០០២/១, កថាខណ្ឌ៦៥៦។

៥៣. សចស បានរកឃើញ *ជាអាទិ៍* ថានៅស្ពានស្រែង "អ្នកយាម ទាំងមាន និងគ្មានអាវុធ នៅថ្នាក់ក្រោមកម្មាភិបាលភូមិភាគនិរតី យាមកាមកម្មករកុំឲ្យរត់គេចខ្លួន ហើយ ចាប់ខ្លួនអ្នកទាំងឡាយណាដែលប្រព្រឹត្តិខុស"[164]។ វាមាន "បរិយាកាសភ័យខ្លាចដែលឃើញកើតមានទូទៅនៅការដ្ឋាននោះ"[165]។ ថា "ការចាប់ខ្លួន និការបាត់ខ្លួនកម្មករឃើញកើតមានជាទូទៅ"[166] ហើយថា "ការចាប់ខ្លួនមានហេតុផលខុសៗគ្នា។ ប្រជាជនត្រូវបានគេចាប់ខ្លួនដោយសារមិនបានធ្វើការងារតាមផែនការការងារ [...] ហេតុផលផ្សេងទៀត រួមមាន ការជាប់ទាក់ទងជាមួយគ្រួសារឧទាហរណ៍ ជាមួយនឹងអ្នកដែលជាប់សាច់ឈាមវៀតណាម ឬ ការប៉ុនប៉ងរត់គេចខ្លួន ឬ ចាកចេញពីការដ្ឋានទៅលេងសមាជិកគញ្រួសារ"[167]។ ដោយសារការរកឃើញទាំងនេះ វាច្បាស់ណាស់ដែលលក្ខខណ្ឌនៃការគាបសង្កត់ និងគួរឲ្យភ័យខ្លាចនៅស្ពានស្រែង និងការបាត់ខ្លួនដែលគ្មានការពន្យល់ជាញឹកញាប់ បានបង្កើតឡើង និងបណ្តាលឲ្យមាននូវការរងឈឺចាប់យ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្តចំពោះពួកជនដែល ត្រូវបានដកចេញ ក៏ដូចជាពួកជនដែលមានជាប់ទាក់ទងជាមួយនឹងពួកគេដែលនៅពីខាងក្រោយ។

## VI. **ទឡ្ហីករណ៍ទី៥÷ សចស មានកំហុសនៅក្នុងអង្គហេតុ នៅពេលដែលរកឃើញថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត**

៥៤. អ៊ឹម ចែម អះអាងដោយមិនត្រឹមត្រូវថាសហព្រះរាជអាជ្ញាខកខានមិនបានភ្ជាប់ទៅនឹងលក្ខខណ្ឌតម្រូវ ដែលថាភស្តុតាងត្រូវតែត្រូវតាមបទដ្ឋានត្រឹមត្រូវនៃសក្ខីកម្ម នៅពេលដែលពិភាក្សាពីកំណត់ហេតុស្តាប់ចម្លើយ DC-Cam របស់គាត់[168]។ អ៊ឹម ចែម ខកខានមិនបានពន្យល់ពីអ្វីដែលគាត់យល់ឃើញ ថាជាការត្រូវទៅតាមបទដ្ឋានត្រឹមត្រូវនៃសក្ខីកម្ម ដើម្បីវាយតម្លៃលើភស្តុតាងនៅក្នុងដំណាក់កាល នេះនៃកិច្ចដំណើរការនីតិវិធី។ យ៉ាងណាក៏ដោយ ដូចដែល សចស បានកត់សម្គាល់ដូច្នោះដែរ ចំណុចចាប់ផ្តើមសម្រាប់ការរកឃើញខាងអង្គហេតុនៅដំណាក់កាលដីកាដំណោះស្រាយគឺផ្អែកលើ "បទដ្ឋានលក្ខខណ្ឌភវនីយភាព [...] មិនមែនលើលក្ខខណ្ឌបទដ្ឋាន [...]

---

164 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៣១។

165 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៣៤។

166 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៣៨។

167 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ២៣៨។

168 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១០៨។

"ដោយគ្មានវិមតិសង្ស័យ" សម្រាប់សេចក្តីសម្រេចផ្តន្ទាទោស បន្ទាប់ពីការជំនុំជម្រះក្តីទេ"[169]។ ដូចដែលបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញា បានបង្ហាញដូច្នោះដែរថា ការទទួលយករបស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងមុខ ដំណែងរបស់គាត់ បានរួមគ្នាជាគូនឹងកំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើជាបមាណីករណ៍ ដែលបានលើសរួចជាស្រេចនូវបទដ្ឋាននៃសក្ខីកម្មនេះ[170]។ ទោះជាយ៉ាងណា សចស មិនបានវាយតម្លៃឱ្យបានត្រឹមត្រូវ ហើយពេលខ្លះ បានចោលភ័ស្តុតាងរបស់សាក្សីដែលពាក់ព័ន្ធ[171]។ មិនមានអ្នកស្វែងរកអង្គហេតុសមហេតុផលណាអាចខកខានមិនបានសន្និដ្ឋានថា អ៊ឹម ចែម បានកាន់មុខតំណែងទាំងអស់នេះឡើយ។

៥៥. បន្ថែមលើនេះ ការលើកឡើងរបស់ អ៊ឹម ចែម ដែលថាការស្តាប់ចម្លើយរបស់គាត់ជាមួយនឹង DC-Cam ដែលត្រូវបាន "ទទួលយកដោយសារវារំលោភទៅលើការការពារប្រឆាំងនឹងការដាក់ពិរុទ្ធឱ្យខ្លួនឯង"[172] គឺមិនសមហេតុសមផលទេ។ សិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង អនុវត្តនៅក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីការពារបុគ្គលម្នាក់កុំឱ្យត្រូវបានបង្ខំឱ្យធ្វើសេចក្តីថ្លែងណាមួយប្រឆាំងនឹងផលប្រយោជន៍របស់ខ្លួន។ ជម្រើសរបស់ អ៊ឹម ចែម ដើម្បីស្ម័គ្រចិត្តផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងតួនាទី មុខដំណែង និង ការទទួលខុសត្រូវ នៅក្នុងរបបខ្មែរក្រហមជូនទៅ DC-Cam និងអង្គការផ្សេងៗទៀត គឺមិនមែនជាមូលដ្ឋានសម្រាប់ការអះអាងណាមួយប្រឆាំងនឹងការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង នោះទេ។ អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង០០២/១ បានធ្វើបដិលេខលើការប្រើប្រាស់របស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពីកំណត់ហេតុស្តាប់ចម្លើយក្រៅតុលាការរបស់ នួន ជា - ទាំងស្តីពី ការពឹងផ្អែកលើផ្នែកដាក់បន្ទុកដែលបានគាំទ្រដោយភស្តុតាងផ្សេងទៀត និងទាំងសេចក្តីសម្រេច របស់ខ្លួនដែលច្រានចោលនូវផ្នែកដោះបន្ទុកបំរើឱ្យខ្លួនឯង

---

169 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ២។ *សូមមើលផងដែរ,* សំណុំរឿង ០០១-**D99** ដីកាបញ្ជូនរឿងទៅជំនុំជម្រះកាំង ហ្គេក់អ៊ាវ ហៅ ឌុច, ១៨ សីហា ២០០៨, កថាខណ្ឌ ១០៣។ ដីកាដំណោះស្រាយសំណុំរឿង ០០២-**D427** ដីកាដំណោះស្រាយ [កោសលុប], ១៦ ធ្នូ ២០១០, កថាខណ្ឌ ១៣២១, ១៣២៣។

170 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ឧទ្ធរណ៍ទី៥, កថាខណ្ឌ ៥៨-៦៩។

171 *សូមមើលផងដែរ* ឧទា., *រដ្ឋអាជ្ញា ទល់នឹង* Perišić, IT-04-81-A, សាលដីកា, ២៨ កុម្ភៈ ២០១៣, កថាខណ្ឌ ៩២, ៩៤; *Protais Zigiranyirazo ទល់នឹង Tiie Prosecutor Caseno*, ICTR-01-73-A, សាលក្រម, ១៦ វិច្ឆិកា ២០០៩, កថាខណ្ឌ ៤៥; *រដ្ឋអាជ្ញា ទល់នឹង* Halilović, IT-01-48-A , សាលក្រម, ១៦ តុលា ២០០៧, កថាខណ្ឌ ១២១; *រដ្ឋអាជ្ញា ទល់នឹង* Kvočka *និងគូកន*., IT-98-30/1-A, សាលក្រម, ២៨ កុម្ភៈ ២០០៥, កថាខណ្ឌ ២៣។

172 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១០៩។ *សូមអាន* ផងដែរ កថាខណ្ឌ១០៧។

ជាក់លាក់មួយចំនួនទៀតផង[173]។ ការទទួលយក របស់ អ៊ឹម ចែម ពាក់ព័ន្ធនឹងមុខដំណែងរបស់គាត់ជាលេខាស្រុកកោះអណ្តែត[174] និងជាសមាជិកគណៈតំបន់១៣[175] គឺត្រូវបានធ្វើបមាណីករណ៍ដោយកំណត់ហេតុសួរចម្លើយ[176]។

៥៦. ប្រព្រឹត្តិកម្មរបស់ អ៊ឹម ចែម អំពីភស្តុតាងដែលបានធ្វើបមាណីករណ៍នោះ ក៏មានខុសឆ្គងផងដែរ។ អំណះអំណាងរបស់ អ៊ឹម ចែម បានក្បត់នូវការខ្វះខាតនៃការយល់ដឹងខាងអង្គហេតុ។ ឧទាហរណ៍ អ៊ឹម ចែម បានស្នើឡើងដោយខុសឆ្គងថា សហព្រះរាជអាជ្ញាដាក់បញ្ចូលគ្នានូវមុខងារជា "*យោធា* ស្រុក និង *លេខា* ស្រុក គឺជាអង្គភាពដាច់ដោយឡែកពីគ្នា"[177]។ ទីមួយ លក្ខន្តិកៈ បកក បានធ្វើឲ្យគណៈស្រុកទទួលខុសត្រូវលើកងកម្លាំងប្រដាប់អាវុធនៅក្នុងស្រុក ដោយផ្តល់អាណត្តិគណៈស្រុកឲ្យ, *ក្នុងចំណោមនោះ,*

> ក្តាប់មហាជន ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្ត ក្នុងក្របខណ្ឌស្រុក របស់ខ្លួនឲ្យជាប់ និងឲ្យណែនជានិច្ច ខាងនយោបាយសតិអារម្មណ៍ និងចាត់តាំង ដោយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ឲ្យជាប់ជានិច្ច ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជា ប្រជាធិបតេយ្យ តាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម របស់បក្ស[178]។

៥៧. ទីពីរ ភស្តុតាង - ដោយរួមទាំង ការទទួលយករបស់ អ៊ឹម ចែម ដែលថា គាត់បានមកដល់ស្រុកព្រះនេត្រព្រះ ជាមួយនឹងកងឈ្លបប្រដាប់អាវុធ ៥០០នាក់ ហើយបានបន្តទៅដកអាវុធពីកងឈ្លប

---

173 **F36** សាលដីកាលើសំណុំរឿង០០២/១, កថាខណ្ឌ ៣៥៨-៣៥៩។

174 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៥, កថាខណ្ឌ ៥៨-៦៩។

175 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៦, កថាខណ្ឌ ៧០-៨១។

176 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទឡ្ហីករណ៍ទី៥, កថាខណ្ឌ ៥៨-៦៩, កថាខណ្ឌ ៧០-៨១។

177 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១១៥។

178 **D1.3.20.1** លក្ខន្តិកៈរបស់ បកក, ខែមករា ឆ្នាំ១៩៧៦, មាត្រា ១៣(២), EN 00184041។

នៅក្នុងស្រុកដែលមានស្រាប់[179] - បង្ហាញថា អ៊ឹម ចែម ក្នុងឋានៈជាលេខាស្រុកនៅក្នុងភូមិភាគពាយ័ព្យ បានត្រួតពិនិត្យលើកងកម្លាំងប្រដាប់អាវុធនៅក្នុងស្រុក[180]។

៥៨. អ៊ឹម ចែម ក៏បានស្វែងរកដោយខុសឆ្គងផងដែរ ក្នុងការធ្វើឱ្យអន្តរាយដល់សាក្សី រៀល សន ដោយមានមូលដ្ឋាននៅលើកង្វះខាតនៃការយល់ដឹងលើភស្តុតាង។ អ៊ឹម ចែមអះអាងថា ភស្តុតាងរបស់ រៀល សន ដែលថា អ៊ឹម ចែម ជា "គណៈឃុំ ហើយក្រោយមកត្រូវបានចាត់តាំងជាគណៈស្រុក"[181] "ផ្តល់តែការគាំទ្រចំពោះសំណើដែលស្នើថាអ្នកស្រី អ៊ឹម ចែម គឺជាសមាជិក "គណៈស្រុក" និងមិនមែនជា *លេខា* ស្រុកទេ"[182]។ ដូចដែលសំណុំរឿងបានបង្ហាញដដែលៗ ដូច្នោះដែរថា សាក្សី និងអ្នកស៊ើបអង្កេតរបស់ កសចស បានប្រើប្រាស់ជាញឹកញាប់នូវពាក្យ "គណៈ" នៅពេលដែលយោងទៅដល់បុគ្គលណាម្នាក់ដើម្បីចង្អុលប្រាប់ថា បុគ្គលនោះឯងជា "លេខា"[183]។

## VII. **ទឡ្ហីករណ៍ទី៦៖ សចស មានកំហុសនៅក្នុងអង្គហេតុ នៅពេលដែលរកឃើញថា អ៊ឹម ចែម មិនមែនជាសមាជិកគណៈតំបន់១៣**

៥៩. ការអះអាងរបស់ អ៊ឹម ចែម ទាក់ទងនឹងការទទួលស្គាល់របស់គាត់ ពាក់ព័ន្ធនឹងមុខដំណែងរបស់គាត់នៅក្នុងតំបន់១៣ បានពឹងផ្អែកលើអំណះអំណាងដូចគ្នានៅពេលដែលគាត់បានជំរុលទៅកាន់

---

179 **D1.3.12.1** កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ឹម ចែម, ២៦ មេសា ២០០៧ EN 00217519 ["ខ្ញុំនាំកម្លាំងពីនិរតីទៅពីតាកែវទៅ ចល័តប្រាំរយ ដាក់តាមការដ្ឋានគេចាស់ហ្នឹង ទាហានប្រាំរយ ប្រជាជនបីខេត្តហ្នឹងក៏យកប្រាំរយគ្រួសារដែរ យករាយតាមភូមិ នៅក្នុងស្រុកទាំងអស់"]។

180 *សូមអាន,* **D304/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម, ២៧ តុលា ២០១៦, ជើងទំព័រ ៦៩០។ *សូមអាន* ផងដែរ, **D119/144** កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាត់ សួយ, ១៨ សីហា ២០១៤, ឆ.៥៣; **D118/242** កំណត់ហេតុនៃការស្តាប់ចម្លើយ ខឹម បឿន, ២១ ឧសភា ២០១៤, ឆ.២៨។

181 **D118/181** កំណត់ហេតុនៃការស្តាប់ចម្លើយ រៀល សន, ១៨ កុម្ភៈ, ឆ.២២៤។

182 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១១៦ (សង្កត់ន័យដើម)។

183 *សូមអាន,* ឧទា., **D219/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ, ៦ តុលា ២០១៤, ឆ.៤២, ឆ.៥០, ស.៥៥, ស.១០៩។ **D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច, ២៨ មករា ២០១៤, ឆ.២៣, ស.២៧, ស៤០, ស.៩៣, ស.៩៤, ស.៩៥, ស.១០៣, ឆ.១០៣។ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់, ២៦ មីនា ២០១៤, ឆ.៤១។ **D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ, ២១ កុម្ភៈ ២០១៤, ឆ.៤២។ **D219/588** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ យ៉ុន, ៥ វិច្ឆិកា ២០១៥, ឆ.៣២។ **D118/278** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណម អ៊ឹម, ២១ កក្កដា ២០១៤, ឆ.២៧។ **D219/4.1** កិច្ចសម្ភាសជាមួយឈ្មោះ សួន ម៉ុត, មជ្ឈមណ្ឌលឯកសារកម្ពុជា, ៨ សីហា ២០១៤, EN 01056790, EN 01056816, 01056819។

ទទ្បីករណ៍ទី៥ ខាងលើ ហើយវាមានកំហុសដូចគ្នា។ បន្ថែមលើនេះ អ៊ឹម ចែម បានបង្ហាញខុសនូវដីកាដំណោះស្រាយ ដោយបានលើកឡើងថា ការស្តាប់ចម្លើយរបស់ DC-Cam "អាចនឹង "ត្រូវបានពឹងផ្អែកតែក្នុងករណីដែលទទួលបានការគាំទ្រដោយប្រភពផ្សេងៗទៀតប៉ុណ្ណោះ""[184]។ តាមពិតទៅ ដីកាដំណោះស្រាយបានធ្វើឡើងដោយការកំណត់ដែលគ្មានមន្ទិល ដោយគ្រាន់តែបានកត់សម្គាល់ពាក់ព័ន្ធនឹង "ការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នដទៃផ្សេងទៀត"[185] (និងដូច្នេះ មិនបានយោងដល់ការស្តាប់ចម្លើយរបស់ DC-Cam ជាពិសេសនោះទេ និងមិនមានការស្តាប់ចម្លើយរបស់ អ៊ឹម ចែម ណាមួយនៅក្នុងការទទួលស្គាល់ជាពិសេសនោះទេ) ដែលថា "គួរត្រូវអនុម័តយក វិធីសាស្ត្រប្រុងប្រយ័ត្នខ្លាំងជាង ក្នុងការវាយតម្លៃទៅលើឯកសារទាំងនោះ ហើយព័ត៌មានដែលមាន នៅក្នុងនោះ គួរត្រូវបានពឹងផ្អែកតែក្នុងករណីដែលបានទទួលការគាំទ្រដោយប្រភពផ្សេងទៀត ប៉ុណ្ណោះ"[186]។ នៅក្នុងការធ្វើអំណះអំណាងរបស់គាត់ដែលថារបាយការណ៍របស់ DC-Cam ស្តីពីការស្តាប់ចម្លើយរបស់គាត់មិនគួរឲ្យទុកចិត្តបាននោះទេ គឺ អ៊ឹម ចែម ខកខានមិនបាន កត់សម្គាល់ថា ការស្តាប់ចម្លើយនេះត្រូវបានកត់ត្រាទុក[187]។ ដូច្នេះ ការស្តាប់ចម្លើយទាំងនេះមានពាក្យ ពេចន៍ផ្ទាល់ខ្លួនរបស់ អ៊ឹម ចែម ហើយចម្លើយតបរបស់គាត់មិនបានផ្តល់នូវសំអាងហេតុណាមួយឡើយ ថាតើហេតុអ្វីបានជាកំណត់ហេតុស្តាប់ចម្លើយផ្ទាល់របស់គាត់មិនត្រូវបានពិចារណាថា គួរឲ្យទុកចិត្តបាន។

៦០. បន្ថែមលើនេះ ផ្ទុយទៅនឹងការអះអាងរបស់ អ៊ឹម ចែម សហព្រះរាជអាជ្ញាគ្រាន់តែបានយោងទៅដល់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថាបានធ្វើបមាណីករណ៍លើភស្តុតាង ដោយការបង្ហាញថា អ៊ឹម ចែម នៅក្នុងគណៈតំបន់១៣[188]។ ការលើកឡើងចោទប្រកាន់របស់គាត់នៅក្នុងរឿងនេះ ហើយដូច្នេះគឺវាដាក់ខុសកន្លែង និងងាយកែសម្រួលបានដោយការពិនិត្យឡើងវិញនូវបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា[189]។

---

184 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២០។

185 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១០៨។

186 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ១០៨។

187 *សូមមើល* ឧទា., **D123/1/5.1cR** CD ថតសំឡេងការសម្ភាស អ៊ឹម ចែម ឆ្នាំ២០១២, ៦ មេសា ២០១២។ **D123/1/5.1bR** CD ថតសំឡេងការសម្ភាស អ៊ឹម ចែម ឆ្នាំ ២០០៨, ២០ មករា ២០០៨។ **D123/1/5.1aR** CD សម្ភាស អ៊ឹម ចែម ឆ្នាំ ២០០៧, ៤ មីនា ២០០៧។

188 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២២។

189 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧៩។

៦១. អ៊ឹម ចែម បានធ្វើការអះអាងដែលមិនមានការគាំទ្រជាស៊េរី ពាក់ព័ន្ធទៅនឹងភាពទាក់ទងគ្នា និងសុចរិតភាពនៃសាក្សីនានាដែលបានផ្តល់ សចស នូវភស្តុតាងពាក់ព័ន្ធនឹងមុខដំណែងរបស់គាត់នៅក្នុងគណ:តំបន់១៣[190]។ ជាឧទាហរណ៍ អ៊ឹម ចែម បានអះអាងថា សហព្រះរាជអាជ្ញា "មិនទទួលស្គាល់" ភស្តុតាងរបស់ ពេជ្រ ជឹម ដែលថា អ៊ឹម ចែម "មិនមែនជាលេខាតំបន់"[191]។ យ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍មិនដែលបានអះអាងថា អ៊ឹម ចែម ជាលេខាតំបន់នោះទេ[192]។ ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា បានដកស្រង់ ភស្តុតាងរបស់ ពេជ្រ ជឹម ថា អ៊ឹម ចែម "នៅក្នុងគណ:តំបន់ និងទទួលខុសត្រូវខាង[កិច្ចការ]នារី" នៅក្នុងតំបន់១៣[193]។ វាមិនមានអ្វីដែលមិនខ្ជាប់ខ្ជួនអំពីកំណត់ហេតុស្តាប់ចម្លើយរបស់ ពេជ្រ ជឹម ដែលថា អ៊ឹម ចែម គឺនៅក្នុងគណ:តំបន់១៣ ប៉ុន្តែមិនមែនជាលេខាតំបន់១៣ នោះទេ។

៦២. ខណៈដែលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា បានស្រង់សម្តីរបស់សាក្សី ប៊ុន ធឿន ថាគាត់បានឮថា អ៊ឹម ចែម គឺនៅក្នុងគណ:តំបន់១៣[194] ដែលផ្ទុយទៅនឹង "គណ:តំបន់១៤" ដូចដែលនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់[195] អ៊ឹម ចែម មិនទទួលស្គាល់នូវអង្គហេតុដែលថា វាមិនមានតំបន់១៤ នៅក្នុងកំឡុងកាលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយថាវាច្បាស់ណាស់ពីភាពទាំងស្រុងនៃកំណត់ហេតុស្តាប់ចម្លើយ ដែលថា ទាំងអ្នកស៊ើបអង្កេតរបស់ សចស ដោយបានសួរសំណួរ និងទាំង ប៊ុន ធឿន បានយោងទៅរកតំបន់ ១៣[196]។

៦៣. បន្ថែមលើនេះ និងដោយផ្ទុយទៅនឹងការអះអាងរបស់ អ៊ឹម ចែម សហព្រះរាជអាជ្ញាមិនបាននិយាយខុសពីភស្តុតាងរបស់ ខឹម បឿន ពាក់ព័ន្ធនឹងថាតើ អ៊ឹម ចែម បាននិយាយអំពីបញ្ហា "សន្តិសុខ ការចាប់ខ្លួនមនុស្ស ខ្មាំង ជនក្បត់ [និង] ការបោសសម្អាត"[197] ដែរ ឬយ៉ាងណានោះទេ។

---

190 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២៤-១៣០។

191 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២៧។

192 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ទទ្ទីករណ៍ទី៦, កថាខណ្ឌ ៧០-៨១។

193 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧៥។

194 **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧៦។

195 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២៧។

196 *សូមអាន* **D118/274** កំណត់ហេតុស្តាប់ចម្លើយរបស់ ប៊ុន ធឿន, ១០ កក្កដា ២០១៤, ឆ.២, ឆ.២០, ឆ.២១, ឆ.២៣, ឆ.៥៨, ឆ.៦៤, ឆ.៧៨។

197 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២៩។

នៅពេលដែលបានសួរថាៈ “តើ អ៊ឹម ចែម ធ្លាប់ឡើងនិយាយអំពីបញ្ហាសន្តិសុខ ឬការចាប់ខ្លួនមនុស្ស ឬខ្មាំង ឬជនក្បត់ ឬក៏ការបោសសម្អាតដែរឬទេ?”[198] ខឹម បឿន បានឆ្លើយតបថា “ប្រសិនបើប្រធានអង្គប្រជុំលើកឡើងអំពីបញ្ហាទាំងអស់នេះគឺមានន័យថា អ៊ឹម ចែម នឹងចាប់អារម្មណ៍ទៅលើបញ្ហាទាំងអស់នោះដែរ”[199]។

៦៤. អ៊ឹម ចែម បានសន្និដ្ឋានថា សាក្សីចំនួន ១១នាក់ និង ដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើបមាណីករណ៍ចំនួនបួននាក់ទៀត ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា[200] រួមគ្នាជាគូជាមួយនឹងការទទួលយកដោយផ្ទាល់ខ្លួនរបស់គាត់ “គឺមានមូលដ្ឋានមិនពេញលេញសម្រាប់អាចទាញការសន្និដ្ឋានណាមួយ” “ដោយយោងទៅលើបន្ទុក និងបទដ្ឋាននៃភស្តុតាង”[201]។ យ៉ាងណាក៏ដោយ វាច្បាស់លាស់ណាស់ដែលថាការទទួលយកជាបមាណីករណ៍របស់ អ៊ឹម ចែម ដែលថា គាត់បានកាន់មុខដំណែងមួយនៅក្នុងគណៈតំបន់១៣ រួចជាស្រេច ដែលបានលើសពី “បទដ្ឋានជាភវនីយភាព” ដែលបានចែងដោយ សចស[202]។

## VIII. **សេចក្តីសន្និដ្ឋាន**

៦៥. អ៊ឹម ចែម ទំនងជាបានទទួលស្គាល់ពីការទទួលខុសត្រូវចំពោះជនរងគ្រោះជាង ២០០០ នាក់ នៅមន្ទីរសន្តិសុខភ្នំទ្រយោង (តែឯង) ដោយបានថ្លែងថា សចស បាន “ធ្វើការវិនិច្ឆ័យដោយយកលំនាំពាក់ព័ន្ធសំខាន់បំផុតនៃភស្តុតាង”[203] និង “សចស បានសន្និដ្ឋានដោយសមហេតុសមផលថានៅពេលពិចារណាក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ចំនួននៃជនរងគ្រោះគឺជាកត្តាដ៏មានឥទ្ធិពលមួយដែលបានជំទាស់នឹងសេចក្តីសន្និដ្ឋានលើបញ្ហាយុត្តាធិការបុគ្គល”[204]។

---

198 **D118/242** កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន, ២១ ឧសភា ២០១៤, ស.99។

199 **D118/242** កំណត់ហេតុស្តាប់ចម្លើយ ខឹម បឿន, ២១ ឧសភា ២០១៤, ឆ.99។

200 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១២៨។

201 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ១៣០។

202 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២។

203 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨៨។

204 **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨៨។

៦៦. ការទទួលយកតែឯងរបស់ អ៊ឹម ចែម នៅលើតួលេខ (ដែលអភិរក្ស[205]) ស្តីពីមនុស្សស្លាប់នៅទីកន្លែងឧក្រិដ្ឋកម្មតែមួយប៉ុណ្ណោះ ដែលនៅក្រោមសិទ្ធិអំណាចរបស់គាត់ គឺថាចំណាត់ថ្នាក់នៃការស្លាប់ ២០០០នាក់ ថាជា ការសម្លាប់រង្គាល ដែលផ្ទុយពី ការធ្វើមនុស្សឃាត គឺមិនអាច "មានឥទ្ធិពលជាសត្យានុម័តនូវការវាយតម្លៃ ថាតើលក្ខខណ្ឌកំណត់នៃយុត្តាធិការបុគ្គលអាចត្រូវបានបំពេញ ឬយ៉ាងណា"[206]។

៦៧. គោលការណ៍ចម្បងនៃចម្លើយតបរបស់ អ៊ឹម ចែម បានផ្តល់នូវចសេចក្តីសន្និដ្ឋាននានាដែលប្រញាប់ប្រញាល់ មិនមានសំអាងហេតុ និង យ៉ាងសង្ខេប នៅពេលដែលសំណុំរឿងត្រូវបានបិទ - ដើម្បីដាក់កម្រិតឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានទៅលើការរកឃើញខាងអង្គហេតុដែលបានតម្រូវដោយ សចស នៅពេលដែលកំណត់រកនូវការខ្វះខាតយុត្តាធិការបុគ្គល។ ការណ៍នេះ បានឆ្លុះបញ្ចាំងពីការប៉ុនប៉ងរបស់ អ៊ឹម ចែម ក្នុងការកម្រិតការបានចូលមើលឯកសាររបស់ សាធារណជន ចំពោះការរកឃើញរបស់ សចស ស្តីពីការស៊ើបសួរជាច្រើនឆ្នាំមកហើយ ដោយការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) ទៅដល់ចំណុចមួយដែលងងឹតឈឹង[207]។ ការកាយកប់នូវអង្គហេតុបែបដូច្នេះ និងលទ្ធផលនៃការវិនិច្ឆ័យលើអង្គច្បាប់បានប៉ះពាល់ដល់កិច្ចដំណើរការ នីតិវិធី សិទ្ធិរបស់ជនរងគ្រោះ និង សាធារណជន។ ហើយវាមិនបានបំរើដល់ផលប្រយោជន៍របស់សាធារណជន ឬខាងយុត្តិធម៌នោះទេ។

## IX. សំណើដែលស្នើសុំ

[205] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ២០៨-២២១។

[206] **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ៨៨។

[207] **D309/2/1/3** ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សម្អាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ), ៤ កញ្ញា ២០១៧។ **D309/1** ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសំណើរបសសហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សេចក្តីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ (D309), ២០ មីនា ២០១៧។ *សូមមើលផងដែរ* **D306** សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំ (១) ចេញដីកាបង្គាប់ឱ្យដកព័ត៌មានចេញប្រឆាំងនឹងព័ត៌មានសង្ខេបនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង (២) ស្នើសុំសហចៅក្រមស៊ើបអង្កេតទាំងពីចេញសេចក្តីថ្លែងការណ៍សាធារណៈរួមមួយ, ១៦ ធ្នូ ២០១៦។

៦៨. ចំពោះសំអាងហេតុខាងលើនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យ អង្គបុរេជំនុំជម្រះ កែតម្រូវកំហុសឆ្គងខាងអង្គច្បាប់ និងអង្គហេតុ ដែលមានរៀបរាប់នៅក្នុងបណ្តឹងឧទ្ធរណ៍ ហើយនិង ឬមួយ៖

(១) បញ្ជូនសំណុំរឿងនេះត្រឡប់ទៅ សចស វិញដោយមានសេចក្តីណែនាំឲ្យពួកគាត់វាយតម្លៃឡើងវិញ ថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះនេះដែរ ឬយ៉ាងណា ឬបើមិនដូច្នោះទេ

(២) សុំឲ្យ អង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់ វាយតម្លៃឡើងវិញនូវសំណុំរឿងនេះ ស្តីពីកំហុសខាងខាងអង្គច្បាប់ និងអង្គហេតុ ដែលមានចែងនៅក្នុងបណ្តឹងឧទ្ធរណ៍៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and stamp] |